សំនួរ_ចំលើយ

ស៊ូ សារិន
សាស្ត្រាចារ្យបរិញ្ញាបត្រ

# ប្រវត្តិវិទ្យា

១១



ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

**សូស្តីប្អូនៗសិស្សានុសិស្សជាទីរាប់អាន!**

សៀវភៅកំណែ **ប្រវត្តិវិទ្យា ៖ ថ្នាក់ទី១១** ត្រូវបានរៀបរៀងឡើង ដើម្បីបំពេញតម្រូវការរបស់ប្អូនៗក្នុងការសិក្សា និងធ្វើការស្រាវជ្រាវដើម្បីបង្កើនចំណេះដឹងចំណេះធ្វើ និងបំនិនប្រសប់នៅក្នុងជីវិត។

សៀវភៅនេះយើងខ្ញុំរៀបរៀងជាលក្ខណៈសំណួរចម្លើយ ស្របតាមកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំយុវជន និងកីឡា។

យើងខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គងដោយអចេតនា ដែលកើតមាននៅក្នុងសៀវភៅកំណែនេះ ហើយយើងខ្ញុំក៏រងចាំទទួលការរិះគន់ និងជួយកែលម្អដោយសេចក្តីសប្បាយរីករាយ។

យើងខ្ញុំសង្ឃឹមថា វានឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ហើយសូមប្អូនៗជួបតែសុខភាពល្អ សុភមង្គល និងទទួលភាពជោគជ័យនៅក្នុងជីវិត។


អ្នករៀបរៀងនិងចងក្រង

**ស៊ុំ សារិន**

**សាស្ត្រាចារ្យបរិញ្ញាបត្រ**

## ជំពូកទី១ ប្រវត្តិសាស្ត្រពិភពលោក

## មេរៀនទី ១ សហរដ្ឋអាមេរិច ( ១៨៦០-១៩១៤)

### សំណួរ-ចម្លើយ

**១. តើមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យប្រជាជនអឺរ៉ុបធ្វើចំណាកស្រុកទៅកាន់ទ្វីបអាមេរិច?**

**ចម្លើយ** មូលហេតុដែលធ្វើឱ្យប្រជាជនអឺរ៉ុបធ្វើចំណាកស្រុកទៅកាន់ទ្វីបអាមេរិច គឺដោយសារ :

- ការរកឃើញទ្វីបអាមេរិចនៅឆ្នាំ1492 ដោយលោកគ្រិស្តុប កូឡំ គឺជាការបន្ទរកំណើនប្រជាជនពីទ្វីបចាស់មកទ្វីបថ្មី
- វិបត្តិសង្គ្រាម និងគ្រោះទុរ្ភិក្ស ដូចជានៅអៀរឡង់ជាដើម ។

**២. ដើម្បីពង្រីកសេដ្ឋកិច្ចសហរដ្ឋអាមេរិច តើរដ្ឋាភិបាលសហព័ន្ធបានអភិវឌ្ឍលើវិស័យអ្វីខ្លះ?**

**ចម្លើយ** ដើម្បីពង្រីកសេដ្ឋកិច្ចសហរដ្ឋអាមេរិច រដ្ឋាភិបាលសហព័ន្ធបានអភិវឌ្ឍលើវិស័យ :

+ **វិស័យកសិកម្ម** : រដ្ឋាភិបាលសហរដ្ឋអាមេរិចបានចេញច្បាប់លំនៅដ្ឋាននៅឆ្នាំ 1862 ដើម្បីលើកទឹកចិត្តដល់ពួកអ្នកដែលមកដល់សហរដ្ឋអាមេរិច ត្រូវបានចំណែកដីធ្លី 65 ហិតតាក្នុងមួយគ្រួសារ។ នយោបាយរបស់រដ្ឋនីមួយៗបានបែងចែកដីចំនួន 20 លានហិតាបន្ថែមទៀត។

+ **វិស័យគមនាគមន៍** : រដ្ឋាភិបាលសហព័ន្ធបានស្ថាបនាផ្លូវរថភ្លើងពីរខ្សែនៅឆ្នាំ 1869។

+ **វិស័យពាណិជ្ជកម្ម** : ក្នុងរយៈពេលតែ 25 ឆ្នាំ ទឹកដីសហរដ្ឋអាមេរិចនៅតំបន់ទំនាបកណ្តាលបានប្រែក្លាយពីតំបន់ព្រៃមកជាតំបន់ពាណិជ្ជកម្មនិងចំការដំណាំខ្វាត់ខ្វែងជាក្រឡាចត្រង្គ។

**៣. ចូរបង្ហាញមូលហេតុដែលនាំឱ្យផ្ទុះសង្គ្រាមបំបែករដ្ឋ និង ផលរបស់វា។**

**ចម្លើយ**

+ **មូលហេតុដែលនាំឱ្យផ្ទុះសង្គ្រាមបំបែករដ្ឋ គឺកើតមានឡើងអំពីបញ្ហាពួកស្បែកខ្មៅ ដោយ :**

- ចាប់តាំងពីឆ្នាំ 1850 នៅរដ្ឋប៉ែកខាងជើងមានចលនាប្រឆាំងមិនឱ្យមានរបបទាសភាពនៅប៉ែកខាងត្បូង ប៉ុន្តែរដ្ឋប៉ែកខាងត្បូងមិនព្រមធ្វើតាមសំណើពួកខាងជើង ដោយខ្លាចបាត់បង់ផលប្រយោជន៍ ពីព្រោះមុខរបរគេទីពឹងដាច់ខាតលើពួកស្បែកខ្មៅ។
- នៅឆ្នាំ 1860 លោកអាប្រាហាមលិងកូល មានគំនិតប្រឆាំងនឹងរបបទាសភាពបានជាប់ឆ្នោតជាប្រធានាធិបតីសហរដ្ឋអាមេរិច ។
- ការគាបសង្កត់បានជំរុញឱ្យរដ្ឋទាំង 11 នៅប៉ែកខាងត្បូងបំបែកចេញពីរដ្ឋសហព័ន្ធដោយបង្កើតរដ្ឋធម្មនុញ្ញមួយដឹកនាំដោយប្រធានាធិបតីថ្មីឈ្មោះ ចេសធឺសុនដាវីស ។

+ លទ្ធផលនៃសង្គ្រាមបំបែករដ្ឋ គឺ

- បានចំណាយជីវិតមនុស្ស 6 សែននាក់
- បន្សល់ទុកនៅទីក្រុងដែលខ្ទេចខ្ទាំ

- ខូចខាតចំការដំណាំធំៗ
- ពួកម្ចាស់ចំការធំៗនៅប៉ែកខាងត្បូងត្រូវវិនាសទ្រព្យសម្បត្តិធ្លាក់ខ្លួនក្រ
- ទាសករស្បែកខ្មៅត្រូវគេដោះលែងឱ្យមានសេរីភាព។

**៤. តាមទ្រឹស្តី ម៉ុនរ៉ូ តើសហរដ្ឋអាមេរិចបានធ្វើអ្វីខ្លះ?**

**ចម្លើយ** តាមទ្រឹស្តី ម៉ុនរ៉ូ សហរដ្ឋអាមេរិច បាន :

- ពង្រីកអាណានិគមនៅតំបន់អាមេរិចកណ្តាល និងអាមេរិចខាងត្បូង
- ដាក់អាណានិគមលើទ្វីបអាស៊ី
- នៅឆ្នាំ 1898 ប្រធានាធិបតី គ្លីវឡិន បានប្រកាសសង្គ្រាមជាមួយនឹងអេស្ប៉ាញ ដើម្បីដណ្តើមប្រទេសភីលីពីននិងប្រទេសគុយបាព្រមទាំងដណ្តើមយកកោះព័រតូរីកូ និងកោះហ្គាមនៅក្នុងលំហមហាសមុទ្រប៉ាស៊ីភិច
- នៅខែតុលា ឆ្នាំ 1983 សហរដ្ឋអាមេរិចបានលើកទ័ពចូលកោះគ្រើណាត។

## មេរៀនទី ២ ប្រទេសចិននិងជប៉ុន( ១៨៤០-១៩១៤)

### សំណួរ-ចម្លើយ

**១. ហេតុអ្វីបានជាចក្រភពអង់គ្លេសគំរាមប្រទេសចិនឱ្យបើកកំពង់ផែ? តើការបើកនេះបានទទួលផលវិបាកដូចម្ដេចខ្លះ ចំពោះប្រទេសចិន?**

**ចម្លើយ**

+ បានជាចក្រភពអង់គ្លេសគំរាមប្រទេសចិនឱ្យបើកកំពង់ផែព្រោះដើម្បីពាណិជ្ជកម្មអង់គ្លេស ។

+ ការទទួលផលវិបាកចំពោះប្រទេសចិន គឺ

- បានបើកទ្វារចំហឱ្យអាភៀនហូរចូលប្រទេសចិនដូចទឹកបាក់ទំនប់
- មានចលនាប៉ះបោរជាច្រើនបានកើតឡើងជាបន្តបន្ទាប់ប្រឆាំងនឹងពួកឈ្លានពាន និងប្រឆាំងនឹងរាជវង្សម៉ាន់ជូ
- វិបត្តិសង្គមរីករាលដាលដោយអំពើពុករលួយនិងការ[illegible]ះជាន់ពីមន្ត្រីម៉ាន់ជូជាអ្នកមានអំណាច

- ពួកអង់គ្លេសបានរកប្អូន រួចដុតបំផ្លាញវាំង
- នៅពេលដែលចិនកំពុងចុះខ្សោយដោយសារសង្គ្រាម ពួកសត្រូវពីខាងក្រៅមានរូស៊ី បានចូលកាន់កាប់ខេត្តម៉ាន់ជូរី និងជប៉ុនក៏បានទាមទារយកខេត្តសានទុងទៅត្រួតត្រាដែរ។

**២. តើសង្គ្រាមអាភៀនលើកទី1 ផ្ទុះឡើងនៅពេលណា? ដំណើរប្រព្រឹត្តទៅនៃសង្គ្រាមដូចម្តេច?**

**ចម្លើយ** សង្គ្រាមអាភៀនលើកទី I ផ្ទុះឡើងនៅព្រះចៅអធិរាជចិនហាមឃាត់មិនឱ្យអង់គ្លេសនាំអាភៀនចូលក្នុងទឹកដីចិន។ពិសេសគឺព្រះចៅអធិរាជ ដាវក្វាង បានបញ្ជាថែមទៀតឱ្យបិទកំពង់ផែក្វាងស៊ូ ព្រមទាំងដេញចាប់កប៉ាល់អាភៀនរបស់អង់គ្លេស, ប៉ុន្តែកប៉ាល់អង់គ្លេសបានគេចរួច ព្រោះមានល្បឿនលឿន។ ព្រឹត្តការណ៍នៅកំពង់ផែក្វាងស៊ូ នេះនាំឱ្យផ្ទុះសង្គ្រាមរវាងចិន និងអង់គ្លេស លើកដំបូងដែលមានឈ្មោះថា សង្គ្រាមអាភៀនលើកទី I ។

\+ **ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម** គឺ ពួកអង់គ្លេសបានបើកឆាកប្រយុទ្ធហើយកាន់កាប់ទីក្រុងក្វាងស៊ូនៅថ្ងៃទី 24 ខែមិថុនា ឆ្នាំ 1842 ប៉ុន្តែត្រូវខូចខាតជាដំណើរដោយសារពួកអ្នកភូមិ សានីយន់លីដែលនៅក្បែរនោះប្រដាប់ដោយ លំពែងនិងចបបានប្រយុទ្ធខ្លួន

ទល់នឹងខ្លួននៅក្រោមដំណក់ទឹកភ្លៀងធ្លាក់ខ្លាំង ធ្វើឱ្យទ័ពអង់គ្លេសប្រើកាំភ្លើងមិនកើត។ ក្រោយពីបរាជ័យ អង់គ្លេសបានបញ្ជូនទ័ពបន្ថែមដណ្តើមយកទីក្រុង ស៊ុយ៉ាមិន ឌីងហៃ និងនីងបូ។ ទ័ពអធិរាជបានបញ្ជូនទៅរំដោះទីក្រុងនីងបូ ប៉ុន្តែត្រូវបរាជ័យ។ បន្ទាប់មកពួកអង់គ្លេសបានវាយយកទីក្រុង សាពូដែលស្ថិតនៅប៉ែកខាងជើងក្រុងសៀងហៃ។ នៅទីនោះពួកអង់គ្លេសបានធ្វើឱ្យខូចខាតជាដំណើរជាលើកទី 2 ដោយសារការទប់ទល់ដោយវីរភាពទាហានម៉ុងកូលមួយកងដែលលាក់ខ្លួនក្នុងផ្ទះឈើបានប្រយុទ្ធលុះតំណក់ឈាមចុងក្រោយ។ ក្នុងដំណើរទៅមុខ អង់គ្លេសបានចូលកាន់កាប់ទីក្រុងសៀងហៃនៅថ្ងៃទី 9 ខែមិថុនា ឆ្នាំ 1842 និងទីក្រុងណានជីងថ្ងៃទី 21 ខែកក្កដា ឆ្នាំ 1842។

**៣. តើសន្ធិសញ្ញាណានជីង មានចំណុចសំខាន់អ្វីខ្លះ? តើអ្នកវាយតម្លៃលើសន្ធិសញ្ញានេះដូចម្តេច?**

**ចម្លើយ** សន្ធិសញ្ញាណានជីង មានចំណុចសំខាន់ដូចខាងក្រោម :

- រដ្ឋាភិបាលចិនត្រូវទទួលសងការខូចខាតជាទឹកប្រាក់ទាំងអស់ 21 លានដុល្លារអាមេរិចក្នុងនោះថ្លៃជំងឺចិត្ត 12 លានដុល្លារ 3 លានដុល្លារទៀតជាប្រាក់ដែលពាណិជ្ជករចិនខ្ចី ចំណែកឯទឹកប្រាក់ 6

លានដុល្លាទៀតជាថ្លៃអាកៀនដែលទាហានចិនបំផ្លាញ។
- ចិនត្រូវបាត់បង់ដែនដីកោះហុងកុងទាំងស្រុង។
- ចិនត្រូវបើកកំពង់ផែចំនួន 5 ទៀតសម្រាប់ពាណិជ្ជករអង់គ្លេស មានក្វាន់ស៊ូ ហ៊ូស៊ូ សាមិន នីងបូ និងសៀងហៃ ចំណែកអង់គ្លេសបានសន្យាសាងសង់រោងចក្រ និងឃ្លាំងនៅតាមកំពង់ផែនិងមានសិទ្ធិរស់នៅនិងដើរហើរសេរីនៅលើទឹកដីចិន។
- ចិនត្រូវកំណត់ពន្ធលើទំនិញនាំចូលឱ្យច្បាស់លាស់ ហើយថេរ និងមិនត្រូវយកពន្ធលើទំនិញទាំងនោះនៅពេលដែលទំនិញនោះចេញផុតពីកំពង់ផែ។
- បើជនជាតិអង់គ្លេសមានការប្រព្រឹត្តខុសនឹងច្បាប់របស់ចិន តុលាការចិនមិនត្រូវជំនុំជម្រះឡើយ គឺត្រូវកាត់ក្តីដោយតុលាការអង់គ្លេសវិញ។

\+ **ចំពោះសន្ធិសញ្ញានេះមិនស្មើភាពគ្នាទេ** គឺអង់គ្លេសជាអ្នកឈ្នះបានដាក់លក្ខខណ្ឌដ៏ធ្ងន់ធ្ងរមកលើប្រទេសចិនដែលជាអ្នកចាញ់ ហើយប្រទេសចិនមិនបានទទួលសិទ្ធិអ្វីទាំងអស់។

**៤. ក្រោយពីធ្វើកំណែទម្រង់រួច តើជប៉ុនបានបង្ហាញខ្លួនឱ្យពិភពលោកស្គាល់ស្វែងតាមរយៈព្រឹត្តការណ៍អ្វីខ្លះ?**

**ចម្លើយ**

ក្រោយពីធ្វើកំណែទម្រង់រួច ជប៉ុនបានបង្ហាញខ្លួនឱ្យពិភពលោកស្ញប់ស្ញែងតាមរយៈព្រឹត្តការណ៍សំខាន់ៗ មាន :

- នៅមុនសង្គ្រាមលោកលើកទី 1 ជប៉ុនបានពង្រីកទឹកដីអាណានិគមទៅលើប្រទេសជិតខាងជាពិសេសទៅលើប្រទេសចិន។
- នៅក្នុងកិច្ចចរចាជប៉ុន-រូស៊ីឆ្នាំ 1904 ដើម្បីចែកតំបន់ត្រួតត្រាបានទទួលបរាជ័យ ធ្វើឱ្យមានការប្រកាសសង្គ្រាមជើងទឹករវាងជប៉ុន-រូស៊ី ដើម្បីត្រួតត្រាតំបន់ម៉ាន់ជូរី នៅខែមិថុនាឆ្នាំ1904។ នៅពេលនោះកងទ័ពជប៉ុនបានយកជ័យជំនះយ៉ាងងាយលើកងទ័ពរូស៊ី ក្នុងដែនទឹកចន្លោះប្រទេសកូរ៉េ និងជប៉ុន។
- ការបញ្ចប់សង្គ្រាមនេះធ្វើឡើងតាមរយៈសន្ធិសញ្ញាជប៉ុន-រូស៊ីនៅទីក្រុងផតម៉ាវ រដ្ឋញូហាមស័រសហរដ្ឋអាមេរិច។ តាមរយៈសន្ធិសញ្ញានេះជប៉ុនមានសិទ្ធិកាន់កាប់តំបន់ម៉ាន់ជូរីនិងចំនួនពាក់កណ្តាលនៃទីប្រជុំកោះសាខាលីនប៉ែកខាងត្បូង។
- នៅឆ្នាំ 1910 ជប៉ុនបានបញ្ចូលប្រទេសកូរ៉េនៅក្នុងទឹកដីអាណានិគមរបស់ខ្លួនទៀត។

## មេរៀនទី

## ៣ ចក្រភពអង់គ្លេស ( ១៨៦៥ -១៩១៤)

### សំណួរ -ចម្លើយ

**១. តើអង់គ្លេសបានដាក់អាណានិគមលើប្រទេសណាខ្លះ?**

**ចម្លើយ** អង់គ្លេសបានដាក់អាណានិគមលើ

- ទ្វីបអាមេរិច ( រដ្ឋទាំង 13 នៅឆ្នាំ 1630)
- ទ្វីបអាស៊ី មាន : ឥណ្ឌា ចិន
- អាស៊ីអាគ្នេយ៍ មាន : ម៉ាឡេស៊ី សិង្ហបុរី មីយ៉ាន់ម៉ា
- ទ្វីបអាហ្វ្រិច
- អៀរឡង់ ...។

**២. ទន្ទឹមនឹងការរីកចម្រើនខាងនយោបាយ តើអង់គ្លេសបានជួបប្រទះនូវវិបត្តិអ្វីខ្លះ?**

**ចម្លើយ**

ទន្ទឹមនឹងការរីកចម្រើនខាងនយោបាយ អង់គ្លេសបានជួបប្រទះវិបត្តិនៅអៀរឡង់ គឺអង់គ្លេសតែជួបប្រទះការបះបោរទាមទារឯករាជ្យពីជនជាតិអៀរឡង់ជារឿយៗ។

**៣. តើកត្តាអ្វីខ្លះដែលជំរុញឱ្យមានបដិវត្តន៍ឧស្សាហកម្មនៅប្រទេសអង់គ្លេស?**

**ចម្លើយ**

កត្តាដែលជំរុញឱ្យមានបដិវត្តន៍ឧស្សាហកម្មនៅប្រទេសអង់គ្លេស គឺដោយសារ :

- ប្រទេសនេះបានប្រមូលផលចំណេញយ៉ាងច្រើនលើសលប់ពីទីផ្សារអាណានិគម។
- កំណើនប្រជាជន គឺជាឃ្លាំងនៃប្រភពធនធានមនុស្សសម្រាប់ជំរុញវិស័យឧស្សាហកម្មឱ្យបានលឿន។ វិស័យនេះបានទាក់ទាញប្រជាជនឱ្យធ្វើបំលាស់ទីពីជនបទមកកាន់ទីក្រុងដែលជាមជ្ឈមណ្ឌលឧស្សាហកម្ម។

- នៅពេលដែលប្រជាជនកើនទីក្រុងក៏រីកធំ ដែលនាំឱ្យមានការរីកចម្រើនថែមទៀតនៅក្នុងវិស័យវប្បធម៌។
- ភាពសម្បូរដោយប្រភពថាមពលក្រោមដីគឺធ្យូងថ្ម ដែលមានច្រើនកន្លែងនៅប្រទេសអង់គ្លេស។ ថាមពលនេះមានតម្លៃថោក។ គេប្រើធ្យូងថ្មសម្រាប់រំលាយដែក និងសម្រាប់ប្រើម៉ាស៊ីនចំហាយទឹក។ ចំណែករ៉ែដែកអង់គ្លេសក៏សម្បូរណាស់ដែរ។
- ចំពោះវិស័យកសិកម្មនៅឆ្នាំ 1815 ប្រទេសអង់គ្លេសបានតំឡើងពន្ធដារលើផលិតផលនាំចូល ដើម្បីកុំឱ្យមានការប្រណាំងខាងតម្លៃសម្រាប់ផលិតផលនៅក្នុងស្រុក។ វិស័យដែលនាំមុខគេនៅក្នុងបដិវត្តន៍ឧស្សាហកម្មគឺវិស័យតម្បាញ។
- រោងឧស្សាហកម្មទាំងអស់បានធានានូវការនាំចេញទៅកាន់ទីផ្សារពិភពលោកទាំងមូល។
- ចំណែកវិស័យដែកថែបវិញ ក៏មានការរីកចម្រើនណាស់ដែរតាមរយៈបច្ចេកទេសគឺអង់គ្លេសបានផលិតដែកថែបនាំមុខគេ។

## មេរៀនទី

## ៣ ចក្រភពអាទ្បឺម៉ង់ ( ១៨៧១ -១៩១៤)

## សំណួរ -ចម្លើយ

**១. អនុលោមទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ1871 តើព្រះចៅអធិរាជមានតួនាទីអ្វីខ្លះនៅក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ?**

**ចម្លើយ**

អនុលោមទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ 1871 ព្រះចៅអធិរាជមានតួនាទីជាប្រមុខនៃរដ្ឋាភិបាលដែលកាន់អំណាចនីតិប្រតិបត្តិ និងជាអ្នកតែងតាំងអធិការបតីឱ្យទទួលខុសត្រូវខាងនយោបាយរដ្ឋ។

**២. តើគណបក្សនយោបាយណាខ្លះ ដែលមានអាសនៈក្នុងសភា?**

**ចម្លើយ**

គណបក្សនយោបាយដែលមានអាសនៈក្នុងសភាមាន :

- **គណបក្សអភិរក្សនិយម** : មានទិសដៅនយោបាយបំរើផលប្រយោជន៍ពួកវណ្ណៈអភិជននិងវណ្ណៈគហបតី។

- **បក្សជាតិសេរីនិយម** : ចូលរួមដោយពួកមូលធនឧស្សាហកម្ម ។
- **គណបក្សកណ្ដាល** : មានទិសដៅនយោបាយថែរក្សាសិទ្ធិរបបរាជានិយម ការពារសិទ្ធិសេរីភាពចលនាវិហារកាតូលិក ដែលកំពុងតែមានចលនាប្រឆាំងនឹងរដ្ឋាភិបាល ។
- **គណបក្សសង្គមប្រជាធិបតេយ្យ** : មានទិសដៅប្រឆាំងនឹងរដ្ឋាភិបាល ហើយមានអាសនៈច្រើននៅក្នុងសភា ។

**៣. តើអធិការបតីប៊ីស្មាក់ មានគោលនយោបាយយ៉ាងណាខ្លះដើម្បីអភិវឌ្ឍន៍ចក្រភពអាឡឺម៉ង់?**

**ចម្លើយ**

ដើម្បីអភិវឌ្ឍន៍ចក្រភពអាឡឺម៉ង់ អធិការបតីប៊ីស្មាក់មានគោលនយោបាយ ដូចខាងក្រោម :

- នៅឆ្នាំ 1971 សភារ៉ៃស្តាកបានអនុម័តច្បាប់ជាវិធានការប្រឆាំងនឹងគណៈសង្ឃកាតូលិច ។
- អធិបតេយ្យនៃរដ្ឋក៏ត្រូវប្រកាសឡើង អាពាហ៍ពិពាហ៍ស៊ីវិលក៏ត្រូវដាក់ឱ្យអនុវត្តជាទូទៅ (កាលពីមុន គេរៀបអាពាហ៍ពិពាហ៍តែតាមផ្លូវសាសនា) ។

សូមអភ័យទោស

ចំពោះទំព័រទី ១៤ - ៣០ អត់មាន

គឺដោយសារនិញប៉ះសៀវភៅខ្វះ

ទំព័រ

អគុណ

- សង្គ្រាមរូស៊ី-ជប៉ុន ។

**៣. តើការលេចឡើងប្លុកយោធា អ៊ីតាលី-អាឡឺម៉ង់-អូទ្រីស-ហុងគ្រី និង បារាំង-អង់គ្លេស-រូស៊ី បានប្រព្រឹត្តទៅយ៉ាងណា?**

**ចម្លើយ** ការលេចឡើងប្លុកយោធា អ៊ីតាលី-អាឡឺម៉ង់-អូទ្រីស-ហុងគ្រី និងបារាំង-អង់គ្លេស-រូស៊ី គឺ

+ **ប្លុកយោធាន អ៊ីតាលី-អាឡឺម៉ង់-អូទ្រីស-ហុងគ្រី** គឺនាដើមសតវត្សទី 20 នៅទ្វីបអឺរ៉ុបបានកើតឡើងនូវសម្ព័ន្ធភាពយោធាពីរដ៏សំខាន់ គឺទីមួយ សម្ព័ន្ធភាពត្រីភាគី ដែលបានកើតឡើងបន្ទាប់ពីសង្គ្រាមបារាំង-ព្រុស ។ លោកអធិការបតី ប៊ីស្មាក់ មានការព្រួយបារម្ភចំពោះស្ថានភាពអាឡឺម៉ង់នៅកណ្ដាលអឺរ៉ុប ។ ដើម្បីការពារដល់សន្តិសុខ អាឡឺម៉ង់បានស្វែងរកសម្ព័ន្ធមិត្តក្នុងបំណងបង្កើតសម្ព័ន្ធភាពយោធា ។ អ្នកដែលមានស្ថានភាពឆ្លើយតបទៅនិងសេចក្ដីត្រូវការរបស់ប្រទេសអាឡឺម៉ង់ គឺប្រទេសមហាអំណាចនៅជិតខាងមានអាណាចក្រអូទ្រីស-ហុងគ្រី និងអ៊ីតាលី ដែលកំពុងមានទំនាស់យ៉ាងស្រួចស្រាវនឹង

ប្រទេសបារាំង ។ដូច្នេះ គេបានចាប់ផ្តើមបង្កើតសម្ព័ន្ធភាពត្រីភាគី អាឡឺម៉ង់ អ៊ីតាលី អូទ្រីស-ហុងគ្រី ។

+ **បារាំង-អង់គ្លេស-រុស្ស៊ី** គឺដោយមានការគំរាមគំហែងពីសំណាក់អាឡឺម៉ង់កាន់តែខ្លាំងឡើងៗ ទីបំផុតអង់គ្លេសបានទទួលស្គាល់ថាគេត្រូវការសម្ព័ន្ធភាពរុស្ស៊ី-បារាំង-អង់គ្លេស ។ ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងត្រីភាគីបែបនេះ ជាដំបូងគេបានដោះស្រាយទំនាស់រវាងរុស្ស៊ី-អង់គ្លេស ជាបឋមនៅអាស៊ីកណ្តាលនិងនៅតំបន់មជ្ឈិមបូព៌ា ។ ជាលទ្ធផលនៃកិច្ចព្រមព្រៀងថ្ងៃទី 31 ខែសីហា 1907 ត្រូវបានចុះហត្ថលេខាលើកតិសញ្ញាអង់គ្លេស-រុស្ស៊ី ស្តីពីតំបន់ក្រោមឥទ្ធិពលរបស់ខ្លួនទៅប្រទេសអ៊ីរ៉ង់ ប្រទេសអាប់កានីស្ថាន និងតំបន់ទីបេ ។ កិច្ចព្រមព្រៀងអង់គ្លេស-រុស្ស៊ី ឆ្នាំ 1907 បានបញ្ចប់គម្រោងបង្កើតសម្ព័ន្ធភាពត្រីភាគី ដែលក្នុងនោះមានអង់គ្លេស-បារាំង-រុស្ស៊ី ។

---

មេរៀនទី

## ៨ សង្គ្រាមលោកលើកទី១ ( ១៩១៤-១៩១៨) និង ការបង្កើតអង្គការសង្គមប្រជាជាតិ

## សំណួរ -ចម្លើយ

**១. ហេតុអ្វីបានជាផ្ទុះសង្គ្រាមលោកលើកទី1? តើប្រទេសណាខ្លះចូលរួម?**

**ចម្លើយ**

\+ បានជាផ្ទុះសង្គ្រាមលោកទី I ព្រោះ

ក. នយោបាយអនុត្តរភាពនៃបណ្តាប្រទេសមហាអំណាច

- សង្គ្រាមរវាងសហរដ្ឋអាមេរិច និងអេស្ប៉ាញ ដើម្បីគ្រប់គ្រងកោះគុយបា (1895-1898) ។
- សង្គ្រាមចក្រភពអង់គ្លេសជាមួយនឹងសាធារណរដ្ឋប៊ួរ (1899-1902) ។ ដើម្បីគ្រប់គ្រងតំបន់ភាគខាងត្បូងនៃទ្វីបអាព្រិច ។
- សង្គ្រាមរូស៊ី-ជប៉ុន (1904-1905) ដើម្បីគ្រប់គ្រងតំបន់អាណានិគមចុងបូព៌ា ។

ខ. វិបត្តិខែកក្កដាឆ្នាំ 1914

នៅថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1914 អូទ្រីស-ហុងគ្រី បានដាក់កំហិតឱ្យស៊ែប៊ី ប្រគល់ឃាតករធ្វើគុតរជ្ជទាយាទឱ្យអូទ្រីស-ហុងគ្រីឱ្យបាន ហើយបានដាក់ឱសានវាទដោយថោកទាបជាទីបំផុត។ រូស៊ីបានឱ្យដំបូន្មានដល់រដ្ឋាភិបាលស៊ែប៊ីឱ្យធ្វើការដកថយដល់កម្រិតអតិបរមានូវអ្វីដែលអាចធ្វើបាន។ ចំណែកអូទ្រីស-ហុងគ្រី និងអាឡឺម៉ង់មិនចង់បានដំណោះស្រាយទំនាស់ដោយសន្តិវិធីនោះទេ។ ថ្ងៃទី 28 ខែកក្កដា ឆ្នាំ 1914 អូទ្រីស-ហុងគ្រីបានប្រកាសសង្គ្រាមនឹងស៊ែប៊ី។

**សរុបមក** កត្តាទាំងពីរខាងលើនេះ ជាមូលហេតុដែលនាំឱ្យកើតនូវសង្គ្រាមលោកលើកទី ១។

+ ប្រទេសចូលរួម មាន : អង់គ្លេស រូស៊ី អាឡឺម៉ង់ ជប៉ុន សហរដ្ឋអាមេរិច សាធារណរដ្ឋប៊ួរ អេស្ប៉ាញ អូទ្រីស ហុងគ្រី ស៊ែប៊ី បារាំង តួគី អ៊ីតាលី ប៊ុលការី ព័រទុយកាល់ ប្រេស៊ីល...។

**២. ហេតុអ្វីបានជាគេធ្វើឃាតលើព្រះអង្គម្ចាស់ប្រង់ស្វាផែឌីណង់?**

**ចម្លើយ**

បានជាគេធ្វើឃាតព្រះអង្គម្ចាស់ប្រង់ស្វាផែឌីណង់ ព្រោះ ដោយសារអូទ្រីស-ហុងគ្រី បានធ្វើតាមការឱ្យដំបូន្មាននៃអធិរាជចក្រភពអាឡឺម៉ង់ ដោយបានសម្រេចចិត្តសំពងទៅលើស៊ែប៊ីមួយអន្លូងដើម្បីបង្ហាញកម្លាំងរបស់ខ្លួននៅក្នុងតំបន់បាល់កង់ ហើយកងទ័ពអូទ្រីស-ហុងគ្រី បានមកឈរជើងនៅក្បែរព្រំប្រទល់ស៊ែប៊ី។ មេដឹកនាំបក្សយោធានិយម និងរជ្ជទាយាទអូទ្រីស-ហុងគ្រីព្រះអង្គម្ចាស់ប្រង់ស្វាផែឌីណង់ បានទៅធ្វើទស្សនកិច្ចក្នុងរដ្ឋធានីសេរ៉ាស៊ីវ៉ូរបស់បូស្នី។ សភាពការណ៍នេះ បានដាស់ដល់អារម្មណ៍ បានដល់អារម្មណ៍យុវជនស្នេហាជាតិស៊ែប៊ីឱ្យពុះកញ្ជ្រោលយ៉ាងខ្លាំង។ ថ្ងៃទី28 ខែមិថុនា ឆ្នាំ 1914 យុវជនជាតិនិយមស៊ែប៊ីពីររូប បានលួចបាញ់ព្រះអង្គម្ចាស់ ប្រង់ស្វាផែឌីណង់នៅតាមដងវិថីមួយនៃទីក្រុងសេរ៉ាស៊ីវ៉ូ។

**៣. តើប្រទេសមហាអំណាចចូលរួមក្នុងសង្គ្រាមចង់បានអ្វី?**

**ចម្លើយ** ប្រទេសមហាអំណាចចូលរួមក្នុងសង្គ្រាម ដើម្បី :

- រដ្ឋាភិបាលអាឡឺម៉ង់ មានទិសដៅបញ្ចប់ការគ្រប់គ្រងរបស់ចក្រភពអង់គ្លេសលើផ្ទៃសមុទ្រ និងធ្វើយ៉ាងណាឱ្យអង់គ្លេសចុះខ្សោយក្នុងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ។
- រដ្ឋាភិបាលអូទ្រីស-ហុងគ្រី មានទិសដៅឈ្លានពានសែប៊ីបង្កើនឥទ្ធិពលរបស់ខ្លួននៅតំបន់ឧបទ្វីបបាល់កង់ កាត់ផ្តាច់ពីស្តេចសារូស៊ីទឹកដីមួយផ្នែកនៃរាជាណាចក្រប៉ូឡូញ ប៉ូដុលនិងវ៉ូលីញ។
- ប្រទេសតួគី បានចូលរួមធ្វើសង្គ្រាមខាងភាគីអាឡឺម៉ង់នៅរដូវស្លឹកឈើជ្រុះឆ្នាំ 1914 មានបំណងឈ្លានពានតំបន់ភ្នំកូកាសនៃស្តេចសាររូស៊ី និងបង្កើតការគ្រប់គ្រងរបស់ខ្លួននៅលើតំបន់បាល់កង់។
- ក្រុមដឹកនាំអង់គ្លេស មានទិសដៅចង់ថែរក្សាប្រទេសអាណានិគមរបស់ខ្លួននិងអំណាចគ្រប់គ្រងផ្ទៃសមុទ្រ កាត់ផ្តាច់ពីតួគីតំបន់សម្បូរប្រេងកាតមេសូប៉ូតាមី និងផ្នែកមួយនៃឧបទ្វីបអារ៉ាប់។

- បារាំង មានបំណងចង់បានតំបន់អាល់សាសនិងឡូរ៉ែនមកវិញ និងផ្នែកមួយនៃឧបទ្វីបអារ៉ាប់ ។

- ស្ដេចសាររូស៊ី មានទិសដៅចង់ថែរក្សាឥទ្ធិពលរបស់ខ្លួននៅក្នុងឧបទ្វីបបាល់កង់ គ្រប់គ្រងតំបន់ហ្កាលីស៊ី តំបន់ណរម៉ាន់ភាគខាងក្រោម គ្រប់គ្រងច្រកចេញពីសមុទ្រខ្មៅ បូស្វ័រនិងដាដាណែល ។

- ជប៉ុន បានប្រកាសសង្គ្រាមនឹងអាឡឺម៉ង់ នាថ្ងៃទី 23 ខែសីហា ឆ្នាំ 1914 មានទិសដៅចូលឈ្លានពានតំបន់ទឹកដីរបស់អាឡឺម៉ង់ ដែលជាប់កិច្ចព្រមព្រៀងជួលពីចិន និងតំបន់កោះក្នុងល្ហាងមហាសមុទ្រប៉ាស៊ីភិច ។

**៤. ហេតុដូចម្ដេចបានជា "សង្គ្រាមផ្លេកបន្ទោរ" មិនបានសម្រេច?**

**<u>ចម្លើយ</u>**

បានជា "សង្គ្រាមផ្លេកបន្ទោរ" មិនបានសម្រេច ព្រោះ ថ្ងៃទី 3-10 ខែកញ្ញា ឆ្នាំ 1914 នៅលើសមរភូមិតាមដងទន្លេម៉ានកងទ័ពឯកភាព បារាំង-អង់គ្លេស បានបញ្ឈប់ការវាយសម្រុកចូលទៅកាន់ប៉ារីសពីសំណាក់កងទ័ពអាឡឺម៉ង់ ។ ក្នុងប្រយុទ្ធនេះមាន

ទាហានចូលរួមចំនួនមួយលានកន្លះ។ ភាគីទាំងសងខាងបានបាត់បង់កម្លាំងប្រហែល៦០០ ពាន់នាក់ទាំងស្លាប់និងរបួស។ លទ្ធផលនៃសង្គ្រាមតាមដងទន្លេម៉ានបានធ្វើឱ្យអាឡឺម៉ង់បោះបង់ចោលគម្រោង "សង្គ្រាមផ្លេកបន្ទោរ"។

**៥. តើកត្តាអ្វីខ្លះ ដែលជំរុញឱ្យសហរដ្ឋអាមេរិចចូលរួមក្នុងសង្គ្រាមលោកលើកទី 1?**

**ចម្លើយ**

កត្តាដែលជំរុញឱ្យសហរដ្ឋអាមេរិចចូលរួមក្នុងសង្គ្រាមលោកលើកទី 1 ព្រោះ :

- ប្រញាប់ប្រញាល់ ដើម្បីចូលរួមក្នុងការទទួលលាភសក្ការៈបានមកពីការបែងចែកពិភពលោកដំណាក់កាលក្រោយសង្គ្រាម។
- នាវាចម្បាំងអាឡឺម៉ង់បានប្រកាសបិទមិនឱ្យនាវាគ្រប់ធុនចូលសំចតកំពង់ផែអឺរ៉ុបដែលជាតំបន់កំពុងផ្ទុះសង្គ្រាម។

**៦. តើសង្គ្រាមលោកលើកទី 1 នាំមកនូវផលវិបាកអ្វីខ្លះ?**

**ចម្លើយ** ផលវិបាកនៃសង្គ្រាមលោកលើកទី ! គឺ

- បាត់បង់ជីវិតមនុស្សអស់ 10 លាននាក់ និងរបួស 20 លាននាក់។
- បាត់បង់ផ្នែកធនធានសម្ភារៈសន្ទីកសន្ទាប់និងប្រជាជនស៊ីវិលជាច្រើនលាននាក់ទៀត។
- សង្គ្រាមបានកំទេចអស់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតមានលំនៅដ្ឋាន ផ្លូវដែក ស្ពាន រោងចក្រ ទីក្រុង . . .។
- ពន្ធដាឡើងខ្ពស់
- ភាពអត់ការងារធ្វើបានធ្លាក់លើស្មាកម្មករ
- សង្គ្រាមបង្កឱ្យមានបដិវត្តន៍ នីងចល់នាប្រជាធិបតេយ្យនិយមដែលមានទិសដៅកែទម្រង់សង្គមដល់ឫសគល់។

---

មេរៀនទី

# ៩ ការបាត់តុល្យភាពក្រោយសង្គ្រាមលោកលើកទី១

## សំណួរ-ចម្លើយ

**១. តើផលវិបាកបន្ទាន់នៃសង្គ្រាមបានធ្វើឱ្យប្រទេសអឺរ៉ុបប្រទះនឹងការលំបាកអ្វីខ្លះ?**

ចម្លើយ ផលវិបាកបន្ទាន់នៃសង្គ្រាមបានធ្វើឱ្យប្រទេសអឺរ៉ុបប្រទះនឹងការលំបាក ដូចខាងក្រោម :

- វិបត្តិសេដ្ឋកិច្ច
- វិបត្តិរូបិយវត្ថុ
- វិបត្តិទីផ្សារ
- វិបត្តិនយោបាយនិងសង្គម ។

**២. ចូររៀបរាប់ពីវិបត្តិសេដ្ឋកិច្ចនៃប្រទេសខ្លះ ក្រោយមហាសង្គ្រាម ។**

ចម្លើយ វិបត្តិសេដ្ឋកិច្ចនៃប្រទេសមួយចំនួនក្រោយមហាសង្គ្រាម :

- ចក្រភពអង់គ្លេស ប្រទេសបារាំង ដែលពីដើមធ្លាប់តែឱ្យគេខ្ចី បានធ្លាក់ខ្លួនក្លាយទៅជាកូនបំណុលរបស់សហរដ្ឋអាមេរិចទាំងអស់។

- អាល្លឺម៉ង់ និងប្រទេសរូស៊ីដែលធ្លាក់ខ្លួនក្រីក្រខ្លាំងពេក គ្មានលទ្ធភាពទិញផលិតផលពីបរទេសបាន បង្ខំចិត្តរស់ដោយខ្លួនឯង ដោយផ្តាច់ទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងប្រទេសផ្សេងៗទាំងអស់។

- សហរដ្ឋអាមេរិចនិងអឺរ៉ុបមានមនុស្សគ្មានការធ្វើចំនួនជាង 30 លាននាក់ ជាហេតុធ្វើឱ្យមានចលាចលខាងនយោបាយ និងសង្គមដែលជាសម្ពាធបង្ខំរដ្ឋាភិបាលនានាឱ្យធ្វើអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ចាប់ពីពេលនោះមក។

**៣. គេពោលថា សេដ្ឋកិច្ចសេរីបានទទួលបរាជ័យនៅពេលក្រោយសង្គ្រាម។ ព្រោះអ្វី?**

**ចម្លើយ**

សេដ្ឋកិច្ចសេរីបានទទួលបរាជ័យនៅពេលក្រោយសង្គ្រាម ព្រោះដោយសារការអនុវត្តនយោបាយរបាំងពន្ធគយ និងនយោបាយ

ឧបត្ថម្ភនិយម ក្នុងវិស័យសេដ្ឋកិច្ចបានធ្វើឱ្យបាត់បង់សេរីភាព ដែលជាគោលការណ៍ទីផ្សារនិយមមួយដ៏សំខាន់នៃមូលធននិយមក្នុងសតវត្សទី ១៧ ។

**៤. តើប្រទេសណាខ្លះ បានកាន់របបផ្តាច់ការនៅមុនសង្គ្រាមលោកលើកទី 2 ?**

**ចម្លើយ**

ប្រទេសបានកាន់របបផ្តាច់ការនៅមុនសង្គ្រាមលោកលើកទី2 មាន ប្រទេសអ៊ីតាលី ប្រទេសអាល្លឺម៉ង់ ប្រទេសអេស្ប៉ាញ ប្រទេសព័រទុយកាល់ ប្រទេសរូស៊ី ប្រទេសអូទ្រីស ហុងគ្រី។

**៥. តើសង្គ្រាមលោកលើកទី1 បានធ្វើឱ្យសង្គមមនុស្សជួបនឹងវិនាសកម្មយ៉ាងណាខ្លះ?**

**ចម្លើយ** សង្គ្រាមលោកលើកទី ១ បានធ្វើឱ្យសង្គមមនុស្សជួបនឹងវិនាសកម្ម ដូចជា :

- មនុស្សជាច្រើនលាននាក់ត្រូវធ្លាក់ខ្លួនចុះក្នុងស្ថានភាពក្រីក្រលំបាកវេទនា រងទុក្ខវេទនា

- គ្មានការងារធ្វើ (កម្មករជាង 30 លាននាក់ត្រូវបាត់បង់ការងាររបស់ខ្លួនក្នុងរោងចក្រ)
- អ្នកដែលធ្លាក់ខ្លួនទាំងនោះច្រើនតែអ្នកមានបៀវត្សតិចតួចស្តួចស្តើង
- ទំនិញឡើងថ្លៃយ៉ាងឆាប់រហ័ស ... ។

**៦. ហេតុអ្វីបានជាជប៉ុនដណ្តើមទីផ្សារអឺរ៉ុបនៅអាស៊ី និង ប៉ាស៊ីភិចបាន?**

<u>**ចម្លើយ**</u> បានជាជប៉ុនដណ្តើមទីផ្សារអឺរ៉ុននៅអាស៊ី និងប៉ាស៊ីភិចបានព្រោះ :

- ជប៉ុនបានខិតខំបង្កើនផលិតផលឧស្សាហកម្មគ្រប់មុខ ដើម្បីប្រកួតប្រជែងជាមួយទ្វីបអឺរ៉ុប ។
- ការរីកចម្រើនខាងនាវាចរណ៍ ជំរុញឱ្យជប៉ុនពង្រីកទីផ្សារលើតំបន់ប៉ាស៊ីភិចខាងកើត អាស៊ីអាគ្នេយ៍និងប្រទេចិន ។
- នៅចន្លោះឆ្នាំ 1913 និង 1918 ជប៉ុនបាននាំចេញផលិតផលឧស្សាហកម្មគិតជាប្រាក់មានចំនួនពី 700 លានយ៉េនទៅដល់ជាង 2 ពាន់លានយោន ។

**៧. តើក្រោយសង្គ្រាមលោកលើកទី 1 បានផ្លាស់ប្តូរផែនទីនយោបាយពិភពលោកយ៉ាងណាខ្លះ?**

<u>**ចម្លើយ**</u> ក្រោយសង្គ្រាមលោកលើកទី 1 បានផ្លាស់ប្តូរផែនទីនយោបាយពិភពលោក គឺ

- បានធ្វើឱ្យសាបសូន្យរបបរាជានិយមជាច្រើននៅទ្វីបអឺរ៉ុប ។
- របបសាធារណរដ្ឋត្រូវបានស្ថាបនាឡើងក្នុងប្រទេសជាច្រើននៅទ្វីបអឺរ៉ុប ។
- ការស្ថាបនារបបផ្តាច់ការបានធ្វើឱ្យមនុស្សភៀសខ្លួនចេញពីរដ្ឋរបស់ខ្លួនជាច្រើន ដោយខ្លាចការគំរាមកំហែងពីអ្នកកាន់អំណាច ដូចជានៅប្រទេសអាឡឺម៉ង់ អ៊ីតាលី អេស្ប៉ាញ ។

**៨. តើវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុ បានញាំញីយ៉ាងណាខ្លះ ដល់ប្រជាជនរងគ្រោះ?**

<u>**ចម្លើយ**</u> វិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុ បានញាំញីដល់ប្រជាជនរងគ្រោះដូចខាងក្រោម :

- ផលិតផលលើសតម្រូវការធ្វើឱ្យថ្លៃផលិតផលហាងទំនិញធំៗបិទទ្វារ ។
- សកម្មភាពពាណិជ្ជកម្មអន្តរជាតិត្រូវបានរាំងស្ទះ ។
- សហរដ្ឋអាមេរិចនិងអឺរ៉ុបមានមនុស្សគ្មានការធ្វើចំនួនជាង 30 លាននាក់ ។



## មេរៀនទី

## ១០ សហភាពសូវៀត ( ១៩១៩-១៩៣៩)

### សំណួរ-ចម្លើយ

**១. តើបដិវត្តន៍ខែកុម្ភៈនិងខែតុលាមានលក្ខណៈខុសគ្នាយ៉ាងណា?**

**ចម្លើយ** បដិវត្តន៍ខែកុម្ភៈ និងខែតុលាមានលក្ខណៈខុសគ្នាត្រង់ :

- បដិវត្តន៍ខែកុម្ភៈ ឆ្នាំ 1917 គឺជាបដិវត្តន៍គហបតីប្រជាធិបតេយ្យផ្តួលរំលំរបបរាជានិយមបង្កើតរបបសភាប្រជាធិបតេយ្យនិយមសេរីពហុបក្ស ។
- បដិវត្តន៍ខែតុលា ឆ្នាំ 1917 គឺបដិវត្តន៍ដណ្តើមអំណាចពីពួកប្រជាធិបតេយ្យ ដោយបក្សបុលសេវិច ដឹកនាំដោយលេនី ។

**២. តើឧបសគ្គអ្វីខ្លះ ដែលសាធារណរដ្ឋសូវៀតរូស៊ីបានជួបប្រទះក្រោយបដិវត្តន៍?**

**ចម្លើយ** : ឧបសគ្គដែលសាធារណរដ្ឋសូវៀតរូស៊ីបានជួបប្រទះក្រោយបដិវត្តន៍ គឺ

**ក. ការប្រឆាំងនឹងបដិវត្តន៍ពីខាងក្នុងប្រទេស**

- ក្នុងរយៈពេលបីឆ្នាំ (1918-1921) សង្គ្រាមផ្ទៃក្នុងមួយបានកើតពាសពេញប្រទេស។ ពួកប្រឆាំងនឹងបដិវត្តន៍ដែលគេហៅថា "ទ័ពទង់ស" បានបង្កើតឡើងដោយទទួលជំនួយឧបត្ថម្ភយ៉ាងចំហពីពួកសម្ព័ន្ធមិត្តចាស់របស់ស្តេចរូស៊ីក្នុងអំឡុងសង្គ្រាមលោកលើកទី I ។
- ជាអវសានពួកប្រឆាំងនឹងបដិវត្តន៍បានត្រូវកំទេចទាំងអស់ក្នុងអំឡុងពេលបីឆ្នាំ។

**ខ. អន្តរាគមន៍បរទេស**

- សម្ព័ន្ធមិត្តចាស់ (បារាំង អង់គ្លេស...) របស់រូស៊ីមិនសប្បាយចិត្តនឹងរូស៊ីដែលស្ថាបនារបបកុំមុយនីសឡើយ គេខិតខំរិះរកគ្រប់ឱកាសដើម្បីធ្វើអន្តរាគន៍កំទេចបដិវត្តន៍ចោល។
- រដ្ឋាភិបាលសូវៀតរូស៊ីបានប្រើអស់សមត្ថភាពរបស់ខ្លួនដើម្បីវាយកំចាត់សត្រូវគ្រប់ទិសទី។ កងទ័ពក្រហមសូវៀត ក្រោមការដឹកនាំរបស់លោកត្រុតស្គី បានធ្វើឱ្យបច្ចាមិត្តគ្រប់សមរភូមិដកខ្លួនថយ។

គ. វិបត្តិរដ្ឋបាល : រៀបចំអង្គការគ្រប់គ្រងនានា និងរៀបចំរដ្ឋ

ធម្មនុញ្ញឡើងវិញ។

ឃ. វិបត្តិសេដ្ឋកិច : កសិកម្ម (បញ្ហាដីស្រែចំការ) ឧស្សាហកម្ម (ទ្រុឌទ្រោម និងអន់ថយ) និងហិរញ្ញវត្ថុ (រៀបចំធនាគារ និង រូបិយប័ណ្ណ)។

ង. វិបត្តិនយោបាយមជ្ឈិមបក្ស : ក្រោយពីលោកលេនីនស្លាប់ អ្នកបដិវត្តន៍មួយចំនួនមិនពេញចិត្តនឹងលោកស្តាលីន...។

**៣. តើសាធារណរដ្ឋសូវៀតរូស៊ី និងសហភាពសូវៀតមានប្រព័ន្ធគ្រប់គ្រងរដ្ឋខុសគ្នាយ៉ាងណា?**

**ចម្លើយ** សាធារណរដ្ឋសូវៀតរូស៊ី និងសហភាពសូវៀតមានប្រព័ន្ធគ្រប់គ្រងរដ្ឋខុសគ្នាដោយ :

**សាធារណរដ្ឋសូវៀតរូស៊ី** : មានប្រព័ន្ធគ្រប់គ្រងរដ្ឋបែបកុំមុយនីស.។

- សហភាពសូវៀត : មានប្រព័ន្ធគ្រប់គ្រងរដ្ឋបែបកុំមុយនីស ហើយបានលុបបំបាត់ចោលអស់នូវវណ្ណៈផ្សេងៗ ក្នុងសង្គម ហើយបានលើកតម្កើងវណ្ណៈពលករនិងអនុវត្តផែនការប្រាំឆ្នាំ។

## មេរៀនទី

## ១១ រដ្ឋអាមេរិច ( ១៩១៩-១៩៣៩)

### សំណួរ-ចម្លើយ

**១. តើមូលហេតុអ្វី ដែលធ្វើឱ្យសហរដ្ឋអាមេរិចក្លាយជាប្រទេសរុងរឿងដោយមានឧទាហរណ៍បញ្ជាក់ផង។**

**ចម្លើយ** មូលហេតុដែលធ្វើឱ្យសហរដ្ឋអាមេរិចក្លាយជាប្រទេសរុងរឿង ព្រោះ

- ជាប្រទេសមានទឹកដីធំទូលាយ ហើយមានធនធានធម្មជាតិដ៏ច្រើនមហិមា។
- ធនធានមនុស្ស និងបច្ចេកទេសខ្ពស់។
- ទឹកដីសហរដ្ឋអាមេរិចពុំមែន ពុំមែនជាសមរភូមិប្រយុទ្ធនៃសង្គ្រាមលោកលើកទី១។
- សហរដ្ឋអាមេរិច ជាអ្នកផលិតអាវុធគ្រប់ធុនសម្រាប់លក់ឱ្យប្រទេសដែលកំពុងធ្វើសង្គ្រាម។

- សហរដ្ឋអាមេរិច ជាប្រទេសដែលមានប្រាក់ច្រើនសន្ទឹក សម្រាប់ឱ្យប្រទេសទាំងឡាយដែលធ្វើសង្គ្រាមខ្ចីបុល ។ ឧទាហរណ៍ ប្រទេសអង់គ្លេស និងបារាំងដែលធ្លាប់មានប្រាក់ឱ្យប្រទេសដទៃខ្ចីក៏ក្លាយជាកូនបំណុលរបស់សហរដ្ឋអាមេរិចដែរ ។

- មកដល់ឆ្នាំ ១៩១៩ រោងចក្រនៅសហរដ្ឋអាមេរិច លែងប្រើប្រាស់ថាមពលចំហាយទឹកទៀតហើយ គឺគេយកថាមពលប្រេងកាត និងអគ្គិសនីមកជំនួសវិញ ដែលធានាការជឿនលឿនក្នុងឧស្សាហកម្ម ។

- ការរៀបចំការងារថ្មី គឺការផលិតតាមស៊េរី និងតាមខ្សែ នាំឱ្យរោងចក្រទាំងឡាយផលិតបានច្រើន ហើយចំណេញពេលវេលាច្រើនលើសលប់ ។

**២. តើ "វឌ្ឍនភាព" តាមបែបសហរដ្ឋអាមេរិចមានឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានយ៉ាងណាខ្លះដល់សង្គម?**

**ចម្លើយ**

\+ **ឥទ្ធិពលវិជ្ជមាន :**

- ធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន
- ប្រជាពលរដ្ឋមានការងារធ្វើគ្រប់ៗគ្នាៗ
- ជីវភាពប្រជាជនមានភាពធូរធារ
- ការរស់នៅប្រកបដោយផាសុកភាព
- មានសម្ភារៈប្រើប្រាស់ទំនើបៗ
- វិទ្យាសាស្ត្រមានភាពជឿនលឿន
- មានសេវាកម្មល្អ
- អាចធ្វើឱ្យគេពង្រីកឥទ្ធិពលទៅលើប្រទេសដទៃទៀត . . .។

**ខ. ផលអវិជ្ជមាន**

- ប្រជាជនឥតការងារធ្វើ
- មានគំលាតរស់នៅរវាងប្រជាជនអ្នកមាន និងប្រជាជនក្រ ដែលរស់នៅដោយស៊ីឈ្នួលគេ
- សហគ្រាសតូចតាចមិនអាច់ឈរជើងបានព្រោះសហគ្រាស ធំៗលេបត្របាក់
- ការរីកចម្រើននាំឱ្យសហរដ្ឋអាមេរិចវាទទីលើប្រទេសដទៃ

- នាំឱ្យមានកំណើនប្រជាជនយ៉ាងឆាប់រហ័សមានការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមជាច្រើនទៀត។

**៣. ហេតុដូចម្តេចបានជាវិស័យកសិកម្មអាមេរិចចាប់ផ្តើមធ្លាក់ចុះតាំងពីឆ្នាំ 1925 មុនវិស័យឧស្សាហកម្ម?**

**ចម្លើយ**

បានជាវិស័យកសិកម្មអាមេរិចចាប់ផ្តើមធ្លាក់ចុះ តាំងពីឆ្នាំ 1925 មុនវិស័យឧស្សាហកម្ម ព្រោះ : កសិករអាមេរិចពុំអាចលក់ផលិតផលរបស់ខ្លួនបាន ព្រោះទីផ្សារនៅអឺរ៉ុបត្រូវបិទទ្វារមួយភាគធំ ហើយតម្លៃចុះថោកបំផុត។

**៤. ចូររៀបរាប់អំពីឥទ្ធិពលនៃព្រឹត្តការណ៍ថ្ងៃអង្គារទី 24 ខែតុលា ឆ្នាំ 1929 "ថ្ងៃអង្គារដ៏ខ្មៅងងឹត" (The Black Tuesday) ចំពោះសហរដ្ឋអាមេរិច និងចំពោះពិភពលោក។**

**ចម្លើយ**

ឥទ្ធិពលនៃព្រឹត្តការណ៍ថ្ងៃអង្គារទី 24 ខែតុលា ឆ្នាំ 1929 "ថ្ងៃអង្គារដ៏ខ្មៅងងឹត" (The Black Tuesday) ចំពោះ សហរដ្ឋ

អាមេរិច និងចំពោះពិភពលោក គឺ

- វិបត្តិកសិកម្ម : ស្ថានភាពកសិកម្មធ្លាក់ចុះដាបតាំងពីឆ្នាំ 1925 បានបន្តចុះដល់កម្រិតទាបបំផុតក្នុងឆ្នាំ 1930 ។
- វិបត្តិឧស្សាហកម្ម : រោងចក្រជាច្រើនបានត្រូវបិទទ្វារ សហគ្រាសអស់មូលធនបន្តៗគ្នា កម្មករគ្មានការងារ មានចំនួន 14 លាននាក់ ដោយពុំបានបញ្ចូលកសិករចំនួន 15 លាននាក់ ដែលរស់នៅខ្វះព្រឹកខ្វះល្ងាចយ៉ាងត្រដាបត្រដួសផងដែរ ។
- វិបត្តិហិរញ្ញវត្ថុ : វិបត្តិហិរញ្ញវត្ថុបានផ្ទុះក្នុងឆ្នាំ 1929 ធនាគារទាំងឡាយត្រូវបិទទ្វារស្ទើរតែទាំងអស់ដោយរកប្រាក់បង្វិលឱ្យអ្នកផ្ញើនិងអ្នកខ្ចីប្រាក់ពុំទាន់បាន ។

**៩. ចូររៀបរាប់អំពី "កម្មវិធីថ្មី (New Deal) " របស់លោកប្រធានាធិបតីប្រង់ឃ្លីនរូស្វែល ។**

**ចម្លើយ** កម្មវិធីថ្មី (New Deal) របស់លោកប្រធានធិបតីប្រង់ឃ្លីនរូស្វែល

- គឺលោកបានបញ្ចុះតម្លៃប្រាក់ដុល្លាពាក់កណ្ដាល និងបើកការដ្ឋានសាធារណៈធំៗ ដើម្បីផ្ដល់ការងារដល់អ្នកគ្មានការងារ ធ្វើនិងធ្វើឱ្យកូនបំណុលធូរស្រាលបន្តិចព្រមទាំងបាន

ទាក់ទាញប្រាក់ដែលកប់ក្នុងទូដែកឯកជនឱ្យមានចលនាឡើងវិញ។ ការផ្តល់ការងារដល់អ្នកគ្មានការងារធ្វើញ៉ាំងពួកគេឱ្យមានប្រាក់កាសនិងធ្វើឱ្យរោងចក្រមានសកម្មភាពឡើងវិញ។

វិធានការកំណែទម្រង់សំខាន់ៗមាន :

- វិធានការខាងកសិកម្ម (ច្បាប់ស្តីពីកំណែទម្រង់ខាងកសិកម្ម)
- វិធានការខាងឧស្សាហកម្ម (ច្បាប់ស្តីពីការលើកស្ទួយឧស្សាហកម្ម)។

---

មេរៀនទី

## ១២ ប្រទេសចិននិងជប៉ុន ( ១៩១៩-១៩៣៩)

### សំណួរ-ចម្លើយ

**១. ហេតុដូចម្ដេចបានជា ស៊ុនយ៉ាត់សេន បានដូរឈ្មោះបក្សរបស់គាត់ពី "បក្សបដិវត្តន៍" ទៅជា "បក្សជាតិនិយម" (ឈុងហ្គោ គួមិញតាង)?**

<u>ចម្លើយ</u>

ដោយការជិះជាន់សង្កត់សង្កិនពីសំណាក់មេដឹកនាំយោធាសក្តិភូមិនិយមនៅតាមតំបន់ផ្សេងៗដោយគាំទ្រពីបរទេសឈ្លានពានផងនោះ បានធ្វើឱ្យប្រជាជនចិនក្តៅក្រហាយយ៉ាងខ្លាំង។ ដោយកត្តានេះហើយទើបលោក ស៊ុនយ៉ាត់សេនបានប្តូរឈ្មោះ "បក្សបដិវត្តន៍" ក្រោមការដឹកនាំរបស់លោកទៅជា "បក្សជាតិនិយម" (ឈុងហ្គោ គួមិញតាង)។

**២. តើក្រោយសង្គ្រាមលោកលើកទី1 របនាសម្ព័ន្ធគ្រប់គ្រងក្នុងប្រទេសចិនមានស្ថានភាពដូចម្ដេច?**

**ចម្លើយ**

ក្រោយសង្គ្រាមលោកលើកទី២ របបនាសម្ពន្ធគ្រប់គ្រងក្នុងប្រទេសចិនវិបត្តិលើផ្លូវនៃរបបមូលធននិយម។ គឺបន្ទាប់ពីមានការបង្រួបបង្រួមកងទ័ពចិនរួចមក អំណោចដែលធ្លាប់តែបានគ្រប់គ្រងដោយសារកម្លាំងកងទ័ពភូមិភាគខាងជើងត្រូវបានផ្លាស់ប្តូរដោយប្រព័ន្ធឯកបក្ស "គួមិញតាង" ដែលមានរបបនាសម្ព័ន្ធដឹកនាំមានគោលនយោបាយបម្រើផលប្រយោជន៍ពួលមូលធននិយមចិន ការពារសម្បត្តិឯកជនពីសំណោក់ពួកក្រុមមនុស្សអត់ទ្រព្យសម្បត្តិ ដឹកនាំសង្គ្រាមប្រឆាំងនឹងពួកកុំមុយនីស។

៣. **ហេតុដូចម្តេចបានជាបក្សជាតិនិយម និងបក្សកុំមុយនីសចិនប្រឈមមុខគ្នា ហើយបង្រួបបង្រួមគ្នាជាសម្ព័ន្ធភាពជាច្រើនលើក?**

**ចម្លើយ**

\+ បក្សជាតិនិយម និងបក្សកុំមុយនីសចិនប្រឈមមុខគ្នាព្រោះបក្សទាំងពីរនេះមានកម្មវិធីនយោបាយដឹកនាំប្រទេសផ្សេងពីគ្នា

។ ម្យ៉ាងទៀតបក្សនីមួយៗបានរៀបចំបង្កើតកម្លាំងមូលដ្ឋានកងទ័ព ដើម្បីធ្វើការតស៊ូបង្កើតក្បាលម៉ាស៊ីនដឹកនាំអំណាចរៀងៗខ្លួន។

+ បក្សទាំងពីរបង្រួបបង្រួមគ្នាជាសម្ព័ន្ធភាព ព្រោះដើម្បីប្រឆាំងនឹងការឈ្លានពានពីបរទេស (ជប៉ុន) មកលើប្រទេសចិនរបស់ពួកគេ។

**៤. តើក្រោយសង្គ្រាមលោកលើកទី I ប្រទេសជប៉ុនមានស្ថានភាពនយោបាយសេដ្ឋកិច្ចដូចម្តេច?**

**ចម្លើយ**

ក្រោយសង្គ្រាមលោកលើកទី I ប្រទេសជប៉ុនមានស្ថានភាពនយោបាយសេដ្ឋកិច្ច ដូចជា :

- នៅឆ្នាំ 1920-1921 វិបត្តិសេដ្ឋកិច្ចបានកើតឡើង នៅក្នុងប្រទេសជប៉ុន ក៏ដូចនៅក្នុងសហរដ្ឋអាមេរិចដែរ។
- នៅឆ្នាំ 1923 គ្រោះធម្មជាតិបានកើតឡើង ដោយការរញ្ជួយដីប៉ះចំលើតំបន់មានមនុស្សរស់នៅកកកុញ។ រាជធានីតូក្យូខ្ទេចខ្ទីទាំងស្រុក មនុស្ស 150 ពាន់នាក់បាត់បង់ជីវិត។

- នៅឆ្នាំ 1924 ស្ថានភាពបានប្រសើរឡើងវិញ ប៉ុន្តែពុំបានបន្តពេលយូរទេនៅឆ្នាំ 1929 ជប៉ុនបានជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចជាថ្មីដូចជាប្រទេសមូលធននិយមដទៃទៀតដែរ ។
- មេដឹកនាំជប៉ុនបានមើលឃើញផ្លូវដំណោះស្រាយមានតែម្យ៉ាងគឺឈានទៅរករបបយោធានិយមបែបថ្មីមួយទៀត ដោយពង្រឹងគោលនយោបាយឈ្លានពានទឹកដីប្រទេសជិតខាង ហើយបង្កើតរបចនាសម្ព័ន្ធដឹកនាំចក្រពត្តិអាណានិគមនិយមក្នុងទិសដៅស្តារ និងលើកកម្ពស់សេដ្ឋកិច្ចប្រទេសជាតិរបស់ខ្លួនដោយដំណាក់កាលចន្លោះសង្គ្រាមលោកទាំងពីរលើកចេញមកពីជួរយោធា-ឧត្តមសេនីយ៍ ឬឧត្តមនាវី ។

**៥. តើនយោបាយចក្រពត្តិនិយមរបស់ជប៉ុន បានប្រព្រឹត្តទៅយ៉ាងណា ដំណាក់កាលមុនសង្គ្រាមលោកលើកទី2 ?**

**ចម្លើយ** នយោបាយចក្រពត្តិនិយមរបស់ជប៉ុន ដំណាក់កាលមុនសង្គ្រាមលោកលើកទី 2 គឺ :

- នៅឆ្នាំ 1927 ឧត្តមសេនីយ៍តាណាកា នាយករដ្ឋមន្ត្រីជប៉ុនបានរៀបគម្រោងធំដើម្បីឈ្លានពានប្រទេសនៅក្នុងទ្វីបអាស៊ី ។

- ដំបូងចូលឈ្លានពានប្រទេសចិន បន្ទាប់មកឥណ្ឌូចិន ភូមា ប្រទេស ផ្សេងៗទៀតនៃតំបន់អាស៊ីអាគ្នេយ៍ ប្រទេសឥណ្ឌា។
- នៅឆ្នាំ 1931 ជប៉ុនបានចាប់ផ្ដើមចូលលុកលុយតំបន់ម៉ាន់ជូរី ហើយគម្រោងឈ្លានពានពង្រីកអំណាចរបស់ជប៉ុនបានចាប់ផ្ដើម។
- នៅឆ្នាំ 1932 ជប៉ុនបានកាន់កាប់ខេត្ត ស៊េហៃ ហើយបានបើកការវាយលុកតម្រង់ទៅកាន់មហាកំពែងចិន។
- នៅឆ្នាំ 1933 ជប៉ុនបានចាកចេញពីសង្គមប្រជាជាតិ។
- នៅខែកក្កដា ឆ្នាំ 1937 បានចាប់ផ្ដើមបើកសមរភូមិវាយលុកទៅលើតំបន់ភូមិភាគខាងជើង និងកណ្ដាលនៃប្រទេសចិន។
- នៅខែតុលា ក្រុងប៉េកាំងត្រូវបានកាន់កាប់ដោយកងកម្លាំងយោធានិយមជប៉ុន ខែវិច្ឆិកា ទីក្រុងសៀងហៃ និងខែធ្នូទីក្រុងណានជីង។

## មេរៀនទី

## ១៣ ប្រទេសអ៊ីតាលីនិងអាល្លឺម៉ង់ ( ១៩១៩ -១៩៣៩)

### សំណួរ -ចម្លើយ

**១. តើមូសូលីនីបានឡើងកាន់អំណាចដឹកនាំរដ្ឋាភិបាលនៃប្រទេសអ៊ីតាលី យ៉ាងដូចម្ដេច?**

ចម្លើយ

មូសូលីនីបានឡើងកាន់អំណាចដឹកនាំរដ្ឋាភិបាល នៃប្រទេសអ៊ីតាលី ដោយគាត់បង្កើតគណបក្សមួយថ្មីហៅថា "គណបក្សផាស៊ីស"។ ក្រោយមកបក្សពួកមូសូលីនីបានធ្វើរដ្ឋប្រហារផ្ដួលរំលំរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

**២. តើអ៊ីត្លែបានឡើងកាន់អំណាចជាអធិការបតី (កាន់ស្លែ) យ៉ាងដូចម្ដេច?**

ចម្លើយ

អ៊ីត្លែបានឡើងកាន់អំណាចជាអធិការបតី (កាន់ស្លែ) ដោយដំបូងអ៊ីត្លែបានចូលជាសមាជិកបក្សកម្មករសង្គមប្រជាធិបតេយ្យ

អាឡឺម៉ង់ ដោយភាពប៉ិនប្រសប់របស់ខ្លួននៅឆ្នាំ 1921 អ៊ីត្លែបាន ក្លាយជាប្រធានបក្ស  នៅពេលនោះបក្សមានឈ្មោះម្យ៉ាងទៀត គឺ  ណាស៊ី។  ក្រោមការដឹកនាំរបស់អ៊ីត្លែបក្សណាស៊ីបានក្លាយ ជាបក្សធំជាងគេ ហើយនៅឆ្នាំ 1933 អំណាចរដ្ឋបានស្ថិតក្រោម ការដឹកនាំរបស់អ៊ីត្លែនិងបក្សរបស់ខ្លួន។

**៣. តើសន្ធិសញ្ញាប៊ែរឡាំង-រ៉ូម (1936) និង រ៉ូម-ប៊ែរឡាំង-តូក្យូ (1937) កើតឡើងដូចម្តេច?**

**ចម្លើយ**

សន្ធិសញ្ញាប៊ែរឡាំង-រ៉ូម (1936) និង រ៉ូម-ប៊ែរឡាំង-តូក្យូ (1937) កើតឡើង ដោយប្រទេសអ៊ីតាលីបានវាយយកប្រទេស អេត្យូពី (1935-1936) ក្នុងទ្វីបអាព្រិចនិងបានគាំទ្រលោកហ្វ្រង់ កូមេផាស៊ីសនៅអេស្ប៉ាញ។ នៅឆ្នាំ 1936 មូសូលីនីបានចងស្ពាន មេត្រីនិងប្រទេសអាឡឺម៉ង់  បន្ទាប់មកនៅឆ្នាំ 1937 ប្រទេស ជប៉ុនបានចូលរួមក្នុងបក្សសម្ព័ន្ធតាមរយៈកតិការសញ្ញា  រ៉ូម-ប៊ែឡាំង-តូក្យូ។

**៤. ប្រៀបធៀបរបបផ្តាច់ការ មូសូលីនី អ៊ីត្លែ និងប៉ុលពតនៅកម្ពុជា។**

**ចម្លើយ** ប្រៀបធៀបរបបផ្តាច់ការ មូសូលីនី អ៊ីត្លែ និងប៉ុលពតនៅកម្ពុជា

- **មូសូលីនី និងហ៊ីត្លែ** : លើកដំកើងជាតិសាសន៍ខ្លួនឯង សំលាប់ជាតិសាសន៍ដទៃ មានគំនិតត្រួតត្រាពិភពលោក . . .។
- **ប៉ុលពត** : សម្លាប់ជាតិសាសន៍ខ្លួនឯង បំផ្លាញស្ថាប័នសង្គម ហើយរណបនយោបាយបរទេស។

**៥. តើលោកអ៊ីត្លែ បានរៀបចំនយោបាយវាតទីរបស់ខ្លួនយ៉ាងណាក្នុងដំណាក់កាលពីឆ្នាំ1933-1939 (មុនសង្គ្រាមលោកលើកទី2)?**

**ចម្លើយ** លោកអ៊ីត្លែបានរៀបចំនយោបាយវាតទីរបស់ខ្លួនក្នុងដំណាក់កាលពីឆ្នាំ 1933-1939 ដោយលោកបានអនុវត្តនយោបាយឈ្លានពាន និងធ្វើអាណានិគមលើប្រទេសទន់ខ្សោយបន្តបន្ទាប់ ។

- ខែកុម្ភៈឆ្នាំ 1938 លោកអ៊ីត្លែបានយកប្រទេសអូទ្រីសមកភ្ជាប់និងរដ្ឋរបស់ខ្លួន។
- ប៉ុន្មានខែក្រោយមកលោកអ៊ីត្លែ បានបែរទៅរកប្រទេសឆេកូស្លូវ៉ាគីម្តងវិញ។ ក្នុងសន្និសីទមយយនៅទីក្រុងមុយនិច ( ថ្ងៃទី 29-30 ខែកញ្ញាឆ្នាំ 1938 ) ប្រទេសអ៊ីតាលី បារាំង អង់គ្លេស បានសម្រេចយកតំបន់ស៊ុយដែតនៃប្រទេសឆេកូស្លូវ៉ាគីទៅឱ្យលោកអ៊ីត្លែ។
- បន្ទាប់ពី យកតំបន់ស៊ុយដែតបានហើយ កងទ័ពអាឡឺម៉ង់មិនអើពើនឹងអ្វីទាំងអស់ បានចូលកាន់កាប់ប្រទេសឆេកូស្លូវ៉ាគីទាំងស្រុងនៅថ្ងៃទី 15 ខែមីនា ឆ្នាំ 1939។

## មេរៀនទី

## ១៤ ប្រទេសបារាំងនិងអង់គ្លេស ( ១៩១៩-១៩៣៩)

### សំណួរ-ចម្លើយ

**១. ចូរប្រៀបធៀបវិបត្តិសេដ្ឋកិច្ចនៅប្រទេសបារាំង និង នៅចក្រភពអង់គ្លេស។**

**ចម្លើយ**

**ក. ប្រទេសបារាំង**

- កសិកម្ម : ផលិតផលកសិកម្មប្រទេសបារាំងសំខាន់ៗដូចជា ស្រាទំពាំងបាយជូរស្រូវសាលី... មិនអាចលក់ចេញទៅក្រៅបាន។ ស្រូវសាលីនិងស្រាទំពាំងបាយជូរនេះ ជាប្រភពសេដ្ឋកិច្ចសំខាន់របស់បារាំង ពីព្រោះប្រជាជនបារាំងប្រមាណ 45% ត្រូវពឹងផ្អែកលើរបរកសិកម្ម។
- វិស័យឧស្សាហកម្ម : រោងចក្រសហគ្រាសជាច្រើនបានបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយផលិតផលត្រូវបន្ថយចុះនៅត្រឹម 2% កម្មករចំនួន 300 ពាន់នាក់គ្មានការងារធ្វើ។

## ខ. ប្រទេសអង់គ្លេស

- ចាប់ពីឆ្នាំ 1919 ឧស្សាហកម្មអង់គ្លេសមានសភាពទ្រុឌទ្រោម ជាខ្លាំងដោយឧបករណ៍ផលិតកម្មមានលក្ខណៈហួសសម័យ។
- ផលិតផលត្បូងថ្មលើសពីតម្រូវការទីផ្សារក្រៅស្រុករួមទាំង ផលិតផលឧស្សាហកម្មអន់ថយមិនអាចប្រកួតប្រជែងនឹង ផលិតផលនៃបណ្តាលប្រទេសថ្មីៗបាន។
- ក្រោយសង្គ្រាមលោកលើកទី I ថាមពលថ្មីៗបានរកឃើញ អាចប្រើជំនួសត្បូងថ្ម ដូចជា ប្រេងកាត អគ្គិសនី ជាហេតុនាំ ឱ្យឧស្សាហកម្មអង់គ្លេសធ្លាក់ចុះថែមទៀត។
- នៅឆ្នាំ 1921 អ្នកអត់ការងារមានចំនួន 2 លាន 5 សែននាក់ ជាហេតុនាំឱ្យមានចលនាផ្សេងៗរំខានរាជរដ្ឋាភិបាល។

<u>**ដូចនេះ**</u> ឆ្លងតាមការបកស្រាយបានឱ្យដឹងថា វិបត្តិសេដ្ឋកិច្ចនៅ ប្រទេសបារាំងមានភាពធ្ងន់ធ្ងរជាងនៅអង់គ្លេស ព្រោះប្រជាជន បារាំងជាង 45% ពឹងផ្អែកលើកសិកម្មមានស្រូវសាលី និងស្រា ទំពាំងបាយជូរ។ សហគ្រាសធំៗត្រូវបិទទ្វារ កម្មករ 3 សែននាក់ គ្មានការងារធ្វើ ផលិតផលក្នុងស្រុកគ្មានទីផ្សារនាំចេញ កម្មករ

। លានាក់ធ្វើការពុំបានពេញម៉ោង បានប្រាក់ខែតិចតួច ព្រោះថៅកែគ្មានប្រាក់បើកឱ្យកម្មករ ។

**២. ចូរប្រៀបធៀបវិបត្តិនយោបាយនៅចក្រភពអង់គ្លេស និងនៅប្រទេសបារាំង ។**

**ចម្លើយ** ប្រៀបធៀបវិបត្តិនយោបាយនៅប្រទេសបារាំង និងនៅអង់គ្លេស :

ប្រទេសអង់គ្លេសជួបវិបត្តិនយោបាយធ្ងន់ធ្ងរជាងប្រទេសបារាំង

- វិបត្តិអត់ការងារធ្វើ និងគណបក្សនយោបាយក្នុងប្រទេស និងវិបត្តិរាជវង្ស
- វិបត្តិនៅប្រទេសអៀឡង់
- វិបត្តិនៅប្រទេសអេស៊ីប
- វិបត្តិនៅប្រទេសឥណ្ឌា
- វិបត្តិផ្សេងៗទៀតនៅកណ្តាប្រទេសក្រោមអាណានិគម ។

**៣. តើមូលហេតុនៃវិបត្តិសេដ្ឋកិច្ចនៅប្រទេសបារាំង និងចក្រភពអង់គ្លេសកើតពីអ្វី?**

**ចម្លើយ** មូលហេតុនៃវិបត្តិទាំងនោះ គឺ :

- ការខូចខាតក្រោយសង្គ្រាមលោកលើកទី I (ហេដ្ឋារចនាសម្ព័ន្ធ . . . )
- មនោគមវិជ្ជាសង្គមនិយ (កុំមុយនីស្ត)
- បញ្ហាទីផ្សារសេរី (ប្រទេសក្រោមអាណានិគម)
- វិបត្តិនយោបាយ (ការបែងចែកគណបក្សច្រើនពេក)
- ការរកឃើញចំហេះថ្មី គឺប្រេងកាត និងអគ្គិសនី និងឧបករណ៍ទាន់សម័យ
- ការប្រកួតប្រណាំងផលិតផលនៃបណ្ដាប្រទេសថ្មីៗ ដូចជា កាណាដា សហរដ្ឋអាមេរិច អាសង់ទីន អូស្ត្រាលី ជប៉ុន...
- ការរីកដុះដាលនៃលទ្ធិប្រជាធិបតេយ្យឆាប់រហ័ស . . .។

**៤. ចូរប្រៀបធៀបវិបត្តិហិរញ្ញវត្ថុរវាងប្រទេសទាំងពីរ តើប្រទេសណាធ្ងន់ធ្ងរជាង។**

**ចម្លើយ** ប្រៀបធៀបវិបត្តិហិរញ្ញវត្ថុរវាងប្រទេសបារាំង និងអង់គ្លេស

វិបត្តិហិរញ្ញវត្ថុនៅប្រទេសបារាំងមានសភាពធ្ងន់ធ្ងរជាងនៅអង់គ្លេស ។

- បារាំងខ្ចីប្រាក់ពីប្រទេសនានាយ៉ាងសន្ធឹកសន្ធាប់ពិសេសពីសហរដ្ឋអាមេរិច
- ប្រទេសបារាំងខូចខាតក្នុងសង្គ្រាមលោកលើកទី ១ ធ្ងន់ធ្ងរ ដូចនេះត្រូវការថវិកា
- ប្រាក់ប្រង់ចុះថោកដូចក្រដាសកាសែត
- ផលិតផលក្នុងស្រុកពុំអាចនាំចេញបាន
- អ្នកអត់ការងារធ្វើច្រើនពេក ។

## មេរៀនទី

## ១៥ បញ្ហាសំខាន់មុនសង្គ្រាមលោកលើកទី២

### សំណួរ-ចម្លើយ

**១. តើសន្ធិសញ្ញាវិមានវែរសៃ (ក្រុងប៉ារីស) បង្ខំឱ្យអាឡឺម៉ង់ធ្វើអ្វីខ្លះ?**

**ចម្លើយ** សន្ធិសញ្ញាវិមានវែរសៃ (ក្រុងប៉ារីស) បង្ខំឱ្យអាឡឺម៉ង់សងប្រាក់ចំនួនទាំងអស់ 138 ពាន់លានម៉ាកជាមាស។

**២. ចូរអធិប្បាយអំពីលក្ខណៈសំខាន់ នៃបញ្ហានៅមជ្ឈិមបូព៌ានៅអឺរ៉ុបកណ្ដាលនិងចុងបូព៌ា។**

**ចម្លើយ** លក្ខណៈសំខាន់នៃបញ្ហានៅមជ្ឈិមបូព៌ា នៅអឺរ៉ុបកណ្ដាល និង ចុងបូព៌ា គឺ

**ក. នៅមជ្ឈិមបូព៌ា**

- មានចលនាជាតិនិយមរបស់ប្រជាជនដែលត្រូវគេជិះជាន់ប្រឆាំងនឹងពួកអាណានិគមនិយម។

- ពួកមហាអំណាចបារាំង-អង់គ្លេសបានធ្វើឱ្យស្ថានភាពនយោបាយកាន់តែតានតឹងខ្លាំងឡើងដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួន ។
- នៅតួគី លោក អួស្តាផាកេម៉ាល់ ដែលគេនិយមហៅកេម៉ាល់អាតាតួកបានធ្វើរដ្ឋប្រហារ ហើយប្រកាសរបបសាធារណរដ្ឋនិយមនៅតួគី ។
- ប្រទេសលីបង់និងស៊ីរី ត្រូវធ្លាក់នៅក្រោមកិច្ចត្រួតត្រារបស់ប្រទេសបារាំង (1920) តាមអាណត្តិរបស់សង្គមប្រជាជាតិ ។
- ការសមគំនិតនៃមហាអំណាចទាំងឡាយ ដើម្បីបង្កើតក្នុងរដ្ឋអារ៉ាប់ ប៉ាលេស្ទីននូវមជ្ឈដ្ឋានមួយសម្រាប់ជនជាតិជ្វីបបានធ្វើឱ្យស្ថានភាពនយោបាយក្នុងតំបន់នេះតានតឹងរហូតនេះតានតឹងរហូតមកដល់សព្វថ្ងៃនេះ ។

## ខ. អឺរ៉ុបកណ្តាល

- ក្រោយចម្បាំង ចក្រភពអូទ្រីស-ហុងគ្រី ត្រូវផុតរលត់ ហើយរដ្ឋថ្មីៗ ជាច្រើនបានចាប់កំណើតនៅតំបន់នោះ ។
- អាណាចក្រអូទ្រីស-ហុងគ្រីចែកចេញជាពីរ គឺរដ្ឋអូទ្រីសមួយនិងរដ្ឋហុងគ្រីមួយទៀត ។

- ដោយយល់ពីគ្រោះថ្នាក់ចំពោះមុខ ប្រទេសឆេកូស្លូវ៉ាគី រូម៉ានី ព្រមព្រៀងគ្នាធ្វើអនុសញ្ញាត្រីភាគីមួយដែលមានបារាំងជាអ្នកជួយគាំទ្រផង។
- សន្ធិសញ្ញាបារាំងបារាំង-ឆេកូស្លូវ៉ាគីឆ្នាំ 1925 បារាំង-រូម៉ានីឆ្នាំ 1926។
- នៅឆ្នាំ 1927 មានធ្វើកិច្ចចុះសន្ធិសញ្ញាបារាំង-យូកូស្លាវី ក្នុងពេលជាមួយគ្នានោះប្រទេសអ៊ីតាលី និងអាឡឺម៉ង់បានគាំទ្រប្រទេសអូទ្រីសនិងប្រទេសហុងគ្រីដែរ។

## គ. នៅចុងបូព៌ា

- ប្រទេសអាឡឺម៉ង់ចាប់ផ្តើមបាត់បង់ទឹកដីគ្រប់គ្រងរបស់ខ្លួននៅប្រទេសចិន។
- ជប៉ុនបានវាយដណ្តើមយកទឹកដីចិនជាច្រើនក្នុងពេលសង្គ្រាមចក្រពត្តិនិយម ជាហេតុបណ្តាលឱ្យអង់គ្លេស បារាំង ពិសេសសហរដ្ឋអាមេរិចពុំសប្បាយចិត្តឡើយ។
- សន្ធិសីទក្រុងវ៉ាស៊ីនតោន ដែលមានអាមេរិចជាអ្នកផ្តើមគំនិតបានតម្រូវឱ្យជប៉ុនប្រគល់តំបន់ខ្លះទៅឱ្យប្រទេសចិន

វិញ ដូចជាខេត្តសានទុងដែលគេដណ្តើមយកពីអាឡឺម៉ង់ ក្នុងពេលសង្គ្រាមជាដើម ។

**៣. តើចាប់ពីឆ្នាំ1938 ដល់ 1939 មានវិបត្តិធំៗអ្វីខ្លះ?**

**ចម្លើយ** ចាប់ពីឆ្នាំ 1938 ដល់ 1939 មានវិបត្តិធំៗ មាន :

- **វិបត្តិនៅឆេកូស្លូវ៉ាគី** : សន្ធិសីទក្រុងមុយនិច ( ថ្ងៃទី 29 ខែកញ្ញា ឆ្នាំ 1938) បានលក់ប្រទេសឆេកូស្លូវ៉ាគី ឱ្យអ៊ីត្លែលើខ្លួនប្រជារាស្ត្រ ។
- សន្ធិសញ្ញាមិនឈ្លានពានគ្នាទៅវិញទៅមក រវាងសូវៀត-អាឡឺម៉ង់ ត្រូវបានចុះហត្ថលេខានៅលើថ្ងៃទី 23 ខែសីហា ឆ្នាំ 1939 ដោយរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសទាំងពីរ ម៉ូឡូតូវ-រីបេនត្រូប ។
- ចំណុចខ្សោយរបស់អង់គ្លេស (ចេមបឺលែន) និងបារាំង (ដាឡាដៀ) ធ្វើឱ្យអ៊ីត្លែបញ្ជូនទ័ពរបស់ខ្លួនចូលទៅវាយលុកប្រទេសប៉ូឡូញ ( ថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 1939) ។

**៤. តើហេតុអ្វីបានជាពួកជាស៊ីសអាឡឺម៉ង់ជាន់ឈ្លីលើសន្ធិសញ្ញាវែរសៃនិងវ៉ាស៊ីនតោន (1919)?**

**ចម្លើយ**

បានជាពួកផាស៊ីស្តអាល្លឺម៉ង់ជាន់ឈ្លីលើសន្ធិសញ្ញាវែរសៃនិងវ៉ាស៊ីនតោន (1919) ព្រោះ នៅឆ្នាំ (1933-1935) កម្មវិធីដ៏សំខាន់របស់ប្រទេសអាល្លឺម៉ង់ គឺលុបបំបាត់ចោលនូវច្បាប់ហាមឃាត់ចំពោះការផលិតសព្វាវុធ ដែលបានសរសេរនៅក្នុងប្រព័ន្ធកិច្ចព្រមព្រៀងវែរសៃ និងរៀបចំត្រៀមខ្លួនដើម្បីធ្វើការបែងចែកពិភពលោកសាជាថ្មី។ កម្មវិធីនយោបាយនេះ ត្រូវបានបិទបាំងដោយគោលនយោបាយស្តារឡើងវិញដើម្បី "សមភាព" អាល្លឺម៉ង់។

**៩. ហេតុដូចម្តេចបានជាលេចឡើងសម្ព័ន្ធភាពយោធាអ៊ីតាលី-អាល្លឺម៉ង់ - ជប៉ុន?**

**ចម្លើយ**

បានជាលេចឡើងសម្ព័ន្ធផាពយោធាអ៊ីតាលី-អាល្លឺម៉ង់-ជប៉ុន ព្រោះ មហាអំណាចបីដែលផ្តួចផ្តើមគំនិតប្រកួតប្រជែងសព្វាវុធ និងចង់បែងចែកពិភពលោកដោយកម្លាំងបាយ បានរៀបចំគម្រោងរបស់ខ្លួនដោយបង្កើតប្លុកយោធាឈ្លានពាន។

មេរៀនទី

## ១៦ សង្គ្រាមលោកលើកទី២ ( ១៩៣៩ -១៩៤៥)

### សំណួរ -ចម្លើយ

**១. តើអ្វីទៅជាសង្គមប្រជាជាតិ?**

**ចម្លើយ**

សង្គមប្រជាជាតិ គឺជាអង្គការអន្តរជាតិមួយដែលបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី១ ដើម្បីធានានូវសន្តិភាពរវាងប្រជាជាតិនានា និងដើម្បីដោះស្រាយទំនាស់នៅក្នុងទំនាក់ទំនងអន្តរជាតិដោយសន្តិវិធី ។ ផ្តើមគំនិតដោយប្រធានាធិបតីសហរដ្ឋអាមេរិច លោក វូដ្រូវិលសុន ។

**២. ហេតុដូចម្តេចបានជាសង្គមប្រជាជាតិអសមត្ថភាពនៅក្នុងការស្វែងរកដំណោះស្រាយទំនាស់អន្តរជាតិ?**

**ចម្លើយ** បានជាសង្គមប្រជាជាតិអសមត្ថភាពនៅក្នុងការស្វែងរកដំណោះស្រាយទំនាស់អន្តរជាតិ គឺ :

- ពុំមានកម្លាំង (ទ័ពពួកខៀវ) គ្រប់គ្រាន់ដើម្បីធានាសន្តិសុខពិភពលោក
- ពុំមានថវិកាសម្រាប់ទ្រទ្រង់បេសកម្ម
- ប្រទេសមហាអំណាចមួយចំនួនមិនគាំទ្រ
- សមាជិកថយចុះជាលំដាប់
- ជាអង្គការអន្តរជាតិមួយបម្រើឱ្យនយោបាយប្រទេសមហាអំណាចនានាដែលមានជាងគេតែប៉ុណ្ណោះ . . .។

**៣. តើនយោបាយមហាអំណាចអាឡឺម៉ង់ និងអ៊ីតាលីផ្តល់វិវត្តដូចម្តេចពីឆ្នាំ 1933-1935 ?**

ចម្លើយ នយោបាយមហាអំណាចអាឡឺម៉ង់ និងអ៊ីតាលីផ្តល់វិវត្តពីឆ្នាំ 1933-1935 ដូចខាងក្រោម :

**ក. អាឡឺម៉ង់**

- ដំណាក់កាលពីឆ្នាំ 1933-1935 បន្ទាប់ពីអ៊ីត្លែឡើងកាន់អំណាចមក ទិសដៅដ៏សំខាន់របស់បក្សណាស៊ី គឺលុបបំបាត់បំរាម ការផលិតសព្វាវុធរបស់អាឡឺម៉ង់ដែលមានចែងក្នុងសន្ធិសញ្ញាសែសៃ។

- ដោយរំលោភបំពានលើសន្ធិសញ្ញាវែរសៃ នៅឆ្នាំ 1935 អាឡឺម៉ង់បានអនុម័តច្បាប់បរិច្ចាគកិច្ចយោធា រួមទាំងឱ្យប្រជាជនអាឡឺម៉ង់រស់នៅតំបន់សារធ្វើប្រជាមតិ ភ្ជាប់តំបន់នេះមកទឹកដីអាឡឺម៉ង់វិញ ។
- ដូច្នេះក្នុងអំឡុងឆ្នាំ 1933-1935 អាឡឺម៉ង់បានផលិតសព្វាវុធ និងពង្រីកទ័ពរបស់ខ្លួនឡើងវិញ ដើម្បីត្រៀមប្រយុទ្ធជាទ្រង់ទ្រាយធំក្នុងនយោបាយឈ្លានពានរបស់ខ្លួន ។

**ខ. អ៊ីតាលី**

ដោយសំអាងទៅលើសិទ្ធិគ្រប់គ្រងប្រទេសអាណានិគមនៅឆ្នាំ 1935 កងទ័ពអ៊ីតាលីបានវាយលុកប្រទេសអេត្យូពី ។ ពួកផាស៊ីសបោះជំហានដំបូងរបស់ខ្លួន ក្នុងការធ្វើសង្គ្រាមមហាអំណាចដោយចំហ ។ នៅឆ្នាំ 1939 សង្គ្រាមបានបញ្ចប់ដោយអ៊ីតាលីបានទទួលជ័យជំនះ ។

**៤. តើមហាអំណាចអាឡឺម៉ង់ អ៊ីតាលី និងជប៉ុនបានរៀបចំយុទ្ធសាស្ត្រនយោបាយរបស់ខ្លួនយ៉ាងណាខ្លះ មុននឹងផ្ទុះសង្គ្រាមលោកលើកទី 2 (1936-1939)?**

**ចម្លើយ** មហាអំណាចអាឡឺម៉ង់ អ៊ីតាលី និងជប៉ុនបានរៀបចំយុទ្ធសាស្ត្រនយោបាយរបស់ខ្លួន មុននឹងផ្ទុះសង្គ្រាមលោកលើកទី 2 (1936-1939) ដូចខាងក្រោម :

- នៅឆ្នាំ 1937 កងទ័ពជប៉ុនដែលឈរជើងស្រាប់នៅតំបន់អ៉ាន់ជូរី បានលុកលុយចូលជ្រៅទៅក្នុងប្រទេសចិនរហូតដល់ទីក្រុងប៉េកាំង។
- នៅខែមីនា ឆ្នាំ 1938 កងទ័ពអាឡឺម៉ង់បានចូលកាន់កាប់ប្រទេសអូទ្រីស ហើយភ្ជាប់ទឹកដីនេះទៅនឹងប្រទេសអាឡឺម៉ង់។
- នៅឆ្នាំ 1938 អាឡឺម៉ង់ទាមទារឱ្យឆេកូស្លូវ៉ាគី ប្រគល់តំបន់ស៊ូដែតដែលស្ថិតក្រោមម៉ាន់ដាតរបស់ខ្លួនមកឱ្យអាឡឺម៉ង់។
- នៅថ្ងៃទី 15 ខែមីនា ឆ្នាំ 1939 ពួកផាស៊ីសអាឡឺម៉ង់បានដាក់ទ័ពចូលកាន់កាប់ទីក្រុងប្រាកនៃប្រទេសឆេកូស្លូវ៉ាគី។

មេរៀនទី

## ១៧ អង្គការសហប្រជាជាតិ (UN)

## សំណួរ -ចម្លើយ

**១. តើកត្តាអ្វីខ្លះជំរុញឱ្យមានការបង្កើតអង្គការសហប្រជាជាតិ?**

**ចម្លើយ** កត្តាជំរុញឱ្យមានការបង្កើតអង្គការសហប្រជាជាតិ គឺ

- ក្នុងទិសដៅរកសន្តិភាពជាសាកលដើម្បីដោះស្រាយវិវាទនិងជម្លោះប្រកកបដោយសន្តិវិធី
- ជាវេទិកានៃកិច្ចចរចាររវាងប្រជាជាតិទាំងអស់លើពិភពលោក
- ពង្រីកទំនាក់ទំនងមិត្តភាពរវាងប្រជាជាតិទាំងឡាយដោយឈរលើការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ
- ធ្វើឱ្យមានសហប្រតិបត្តិការអន្តរជាតិផ្សេងៗ ផ្នែកសេដ្ឋកិច្ចនិងសង្គម ប្រាជ្ញា និងមនុស្សធមិ ដោយគ្មានប្រកាន់ពូជសាសន៍ ភេទ ភាសា និងសាសនា។
- ស្ថិតនៅក្នុងក្របខណ្ឌដែលប្រជាជាតិនានា ខិតខំប្រឹងប្រែងឆ្ពោះទៅរកសេដ្ឋកិច្ចរួមមួយ ...។

**២. ហេតុដូចម្ដេច បានជាអង្គការអន្តរជាតិនេះ ដាក់ឈ្មោះថាជាអង្គការសហប្រជាជាតិ?**

**ចម្លើយ**

បានជាអង្គការអន្តរជាតិនេះ ដាក់ឈ្មោះថាជាអង្គការសហប្រជាជាតិ ព្រោះអង្គការនេះប្រទេសជាច្រើននៅលើពិភពលោកចូលជាសមាជិក។ ហើយការបង្កើតឈ្មោះអង្គការនេះ គឺជាប់ទាក់ទងនឹងប្រធានាធិបតីអាមេរិចដ៏ល្បីល្បាញម្នាក់ ដែលពលរដ្ឋអាមេរិចបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត 4 អាណត្តិជាប់គ្នា គឺលោកប្រង់ឃ្លីន រូស្វែល។

**៣. តើមានស្ថាប័នអ្វីខ្លះ ស្ថិតនៅជាយន្តការអង្គការសហប្រជាជាតិ?**

**ចម្លើយ** ស្ថាប័នដែលស្ថិតនៅជាយន្តការអង្គការសហប្រជាជាតិមាន:

- មហាសន្និបាត
- ក្រុមប្រឹក្សាសន្តិសុខ
- ក្រុមប្រឹក្សាភិបាល
- តុលាការអន្តរជាតិ

- លេខាធិការដ្ឋាន

- ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ។

**៤. តើអគ្គលេខាអង្គការសហប្រជាជាតិមានប៉ុន្មានរូប? ឈ្មោះអ្វី? បញ្ជាក់ពីសញ្ជាតិផង ។**

**ចម្លើយ** អគ្គលេខាអង្គការសហប្រជាជាតិមាន 8 រូប គឺ

- លោក ទ្រីវលី (1946-1952) សញ្ជាតិណេរវែស
- លោក ដាក់ម៉ាម៉ាសូល (1953-1961) ជនជាតិស៊ុយអ៊ែត
- លោក អ៊ូថាន់ (1961-1971) ជនជាតិភូមា
- លោក គៀតវ៉ាលហែម (1972-1981) ជនជាតិអូទ្រីស
- លោក សាវីយេប៉េរេដឺគូអេឡា (1982-1991) ជនជាតិប៉េរូ
- លោក ប៊ូត្រូសប៊ូត្រូសកាលិ (1992-1997) ជនជាតិអេស៊ីប
- លោក កូហ្វីអានណាន់ (1997-2006) ជនជាតិកាណា
- លោក បានគីមូន (2007-2012) ជនជាតិកូរ៉េ ។

---

## ?សំណួរបញ្ចប់ជំពូកទី១

I. *ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ៖*

១. តើប្រធានាធិបតីសហរដ្ឋអាមេរិចរូបណាដែលប្រឆាំងនឹងរបបទាសភាព (ប្រកាន់ពូជសាសន៍)?

☐ក. វ៉ាស៊ីនតោន ☑ខ. លីងកូល

☐គ. ម៉ុនរ៉ូ ☐ឃ. គ្លីនតុន

២. តើប្រទេសណានាំអាភៀនទៅលក់នៅប្រទេសចិន?

☐ក. បារាំង ☑ខ. អង់គ្លេស

☐គ. ជប៉ុន ☐ឃ. អាឡឺម៉ង់

៣. តើហេតុអ្វីបានជាអង់គ្លេសហាមមិនឱ្យប្រទេសក្រោមអាណានិគមផលិតដូចផលិតផលខ្លួន?

☐ក. ខ្លាចអត់គុណភាព ☐ខ. ខ្លាចនៅសល់

☑គ. ខ្លាចប្រណាំងប្រជែង ☐ឃ. ល្អជាង

II. ចូរជ្រើសរើសពាក្យ កន្សោមពាក្យឆ្នាំ ឬឈ្មោះទៅបំពេញឈ្មោះខាងក្រោម

(សហរដ្ឋអាមេរិច, អេស្ប៉ាញ, 23 សីហា 1914, សេដ្ឋកិច្ច, ស៊ុនយ៉ាត់ សេន, 28 មេសា 1945)

១. នៅថ្ងៃទី...*28*..ខែ...***មេសា***...ឆ្នាំ...*1945*...មូសូលីនីត្រូវបានចាប់ខ្លួននិងកាត់ទោសប្រហារជីវិត។

២. នៅឆ្នាំ1923 លោក ...***ស៊ុនយ៉ាត់សេន***... (ចិន) បានផ្ដើមធ្វើកំណែទម្រង់បក្សជាតិនិយមចិន។

៣. សង្គ្រាមរវាង...***សហរដ្ឋអាមេរិច***... និង ...***អេស្ប៉ាញ***... ដើម្បីគ្រប់គ្រងកោះគុយបា (1895-1898)។

III. *ចូរគូសភ្ជាប់ ឬ ផ្គូផ្គងក្នុងប្រអប់ខាងក្រោម*

| ឈ្មោះប្រទេស | ឈ្មោះថ្នាក់ដឹកនាំ | ចម្លើយ |
|---|---|---|
| ១. អង់គ្លេស | ក. ស្តាលិន | ១. → គ |
| ២. សហភាពសូវៀត | ខ. អ៊ីត្លែ | ២. → ក |
| ៣. សហរដ្ឋអាមេរិច | គ. ឆឺឈីល | ៣. → ង |
| ៤. អ៊ីតាលី | ឃ. មូសូលីនី | ៤. → ឃ |
| ៥. អាឡឺម៉ង់ | ង. រ៉ូស្វែល | ៥. → ខ |

## IV. សំណួរត្រិះរិះ

**១. តើហេតុអ្វីបានជាមានសង្គ្រាមលោកលើកទី1? តើលទ្ធផលយ៉ាងណា?**

**ចម្លើយ**

\+ **បានជាផ្ទុះសង្គ្រាមលោកទី 1 ព្រោះ**

ក. នយោបាយអនុត្តរភាពនៃបណ្តាប្រទេសមហាអំណាច

- សង្គ្រាមរវាងសហរដ្ឋអាមេរិច និងអេស្ប៉ាញ ដើម្បីគ្រប់គ្រងកោះគុយបា (1895-1898) ។
- សង្គ្រាមចក្រភពអង់គ្លេសជាមួយនឹងសាធារណរដ្ឋប៊ួរ (1899-1902) ។ ដើម្បីគ្រប់គ្រងតំបន់ភាគខាងត្បូងនៃទ្វីបអាព្រិច ។
- សង្គ្រាមរូស៊ី-ជប៉ុន (1904-1905) ដើម្បីគ្រប់គ្រងតំបន់អាណានិគមចុងបូព៌ា ។

**ខ. វិបត្តិខែកក្កដាឆ្នាំ 1914**

នៅថ្ងៃទី 23 ខែកក្កដា ឆ្នាំ 1914 អូទ្រីស-ហុងគ្រី បានដាក់កំហិតឱ្យស៊ែប៊ីប ប្រគល់ឃាតករធ្វើគុតរជ្ជទាយាទឱ្យអូទ្រីស-ហុងគ្រីឱ្យបាន ហើយបានដាក់ឱសានវាទដោយថោកទាបជាទី

បំផុត។ រូស៊ីបានឱ្យដំបូន្មានដល់រដ្ឋាភិបាលស៊ែប៊ីឱ្យធ្វើការដក ថយដល់កម្រិតអតិបរមានូវអ្វីដែលអាចធ្វើបាន។ ចំណែក អូទ្រីស-ហុងគ្រី និងអាល្លឺម៉ង់មិនចង់បានដំណោះស្រាយទំនាស់ ដោយសន្តិវិធីនោះទេ។ ថ្ងៃទី 28 ខែកក្កដា ឆ្នាំ ១៩១៤ អូទ្រីស-ហុងគ្រីបានប្រកាសសង្គ្រាមនឹងស៊ែប៊ី។

**សរុបមក** កត្តាទាំងពីរខាងលើនេះ ជាមូលហេតុដែលនាំឱ្យកើត នូវសង្គ្រាមលោកលើកទី១។

**ផលវិបាកនៃសង្គ្រាមលោកលើកទី ១ គឺ**

- បាត់បង់ជីវិតមនុស្សអស់ 10 លាននាក់ និងរបួស 20 លាននាក់។
- បាត់បង់ផ្នែកធនធានសម្ភារៈសព្វាកសព្វាប់ និងប្រជាជនស៊ីវិល ជាច្រើនលាននាក់ទៀត។
- សង្គ្រាមបានកំទេចអស់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតមាន លំនៅដ្ឋាន ផ្លូវដែក ស្ពាន រោងចក្រ ទីក្រុង ...។
- ពន្ធដាឡើងខ្ពស់
- ភាពអត់ការងារធ្វើបានធ្លាក់លើស្នាកម្មករ

- សង្គ្រាមបង្កឱ្យមានបដិវត្តន៍ និងចលនាប្រជាធិបតេយ្យនិយម ដែលមានទិសដៅកែទម្រង់សង្គមដល់ឫសគល់ ។

**២. តើសង្គ្រាមលោកលើកទី2 បានបំផ្លាញអ្វីខ្លះ? តើអ្នកគិតដូចម្តេច?**

**ចម្លើយ** សង្គ្រាមលោកលើកទី2 បានបំផ្លាញ :

- អូសទាញប្រទេសចំនួន 72 ឱ្យចូលរួម ។
- មនុស្សប្រមាណ 62 លាននាក់ជាជនពិការ ។
- បាត់បង់ជីវិតមនុស្សច្រើនមហិមា ចំនួន 55 លាននាក់ ក្នុងចំណោមនោះ ទ្វីបអឺរ៉ុបបាត់បង់ 45 លាននាក់ ។ ចំណែកទ្វីបអាស៊ី ប្រទេសចិនបានបាត់បង់មនុស្សជាង 20 លាននាក់ ប្រទេសជប៉ុនបានបាត់បង់អស់ 2.3 លាននាក់ ។
- ទីក្រុងមួយចំនួនត្រូវបានបំផ្លាញ ។
- ហេដ្ឋារចនាសម្ព័ន្ធសង្គមក៏ត្រូវបានបំផ្លាញ . . . ។

\+ សង្គ្រាមលោកលើកទី2 ជាសង្គ្រាមមួយដែលបំផ្លាញពិភពលោកឱ្យខូចខាតជាដំណាំដែលពុំធ្លាប់មានពីមុនមក ។ ដូច្នេះពិភពលោកគួររស់នៅជាមួយគ្នាប្រកបដោយសុខសន្តិភាព និងភាតរភាព

ការឃោគយល់អធ្យាស្រ័យគ្នា នៅក្រោមការដឹកនាំរបស់អង្គការសហប្រជាជាតិតែមួយ គឺធ្វើយ៉ាងណាបញ្ចៀសរាល់សង្គ្រាមទាំងឡាយ និងរកដំណោះស្រាយដោយសន្តិវិធី ។

**៣. តើសង្គ្រាមលោកទាំង 2 លើក ផ្តល់ផលវិបាកអ្វីខ្លះ?**

**ចម្លើយ** សង្គ្រាមលោកទាំង2លោក ផ្តល់ផលវិបាកដូចខាងក្រោមៈ

- បំផ្លាញជីវិតមនុស្សអស់ជាច្រើនលាននាក់
- បំផ្លាញសម្ភារៈ
- បំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិ
- បំផ្លាញទីក្រុងមួយចំនួនឱ្យខូចខាត
- ធ្វើឱ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ
- មនុស្សអត់ការងារធ្វើ
- ប្រទេសមួយចំនួនត្រូវជំពាក់បំណុលគេ
- ចំណាយថវិកាយ៉ាងច្រើនសន្ធឹកដើម្បីស្តារសង្គមជាតិឡើងវិញ ។

# ជំពូកទី២ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

## មេរៀនទី ១ សម័យចតុមុខ ( សតវត្សទី១៥)

### សំណួរ -ចម្លើយ

**១. តើហេតុអ្វីបានជាព្រះពញាយ៉ាតជ្រើសតាំងរាជធានីចតុមុខមង្គល?**

**ចម្លើយ** បានជាព្រះពញាយ៉ាតជ្រើសតាំងរាជធានីចតុមុខមង្គល ព្រោះ ដើម្បី :

- ការពារខ្លួនពីសំណាក់សត្រូវសៀម។
- នៅចតុមុខមានទីតាំងល្អ សម្រាប់ស្តារជីវភាពប្រជារាស្ត្រ ដែលបានធ្លាក់ចុះយ៉ាងគំហុកដោយសារសៀមចូលឈ្លានពានជាច្រើនសា។
- ភាគខាងត្បូង មានចំនួនប្រជាជនច្រើនជាងដែលងាយស្រួលក្នុងការប្រមូលកម្លាំងប្រជាជន និងកសាងប្រទេសជាតិ។
- ដីមានជីជាតិងាយស្រួលក្នុងការបង្កបង្កើនផល។

- នៅតំបន់ចតុមុខងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មទាំងផ្លូវគោក និងផ្លូវទឹក ... ។

**២. តើមូលហេតុដែលព្រះស្រីរាជាមិនអាចរំដោះខេត្តខាងលិចពីសៀមបាន?**

**ចម្លើយ** មូលហេតុដែលព្រះស្រីរាជាមិនអាចរំដោះខេត្តខាងលិចពីសៀមបាន ព្រោះដោយសារមានវិបត្តិរាជវង្សានុវង្សយ៉ាងធ្ងន់ធ្ងរ ដូចជា ស្រីសុរិយោទ័យបានដកខ្លួនពីចតុមុខទៅបង្ករាជអំណាចនៅស្រីសន្ធរ ធម្មរាជាល្មោភអំណាចបានពឹងសៀមឱ្យមកជួយដណ្តើមរាជ្យ ។

**៣. តើហេតុអ្វីបានជាប្រទេសខ្មែរចែកជាបីអាណាចក្រ?**

**ចម្លើយ** បានជាប្រទេសខ្មែរចែកជាបីអាណាចក្រ ព្រោះដោយការដណ្តើមរាជរវាងព្រះបាទធម្មរាជា ព្រះបាទស្រីសុរិយោទ័យ ពីព្រះបាទស្រីរាជា ។

**៤. វិបត្តិទាំងនេះបានផ្តល់ផលវិបាកអ្វីខ្លះ ដល់សង្គមនិងប្រជារាស្ត្រខ្មែរ?**

**ចម្លើយ** វិបត្តិទាំងនេះ បានផ្តល់ផលវិបាកដល់សង្គម និងប្រជារាស្ត្រខ្មែរ ដូចខាងក្រោម :

- បង្កឱ្យមានចោរកម្ម ឆក់ប្លន់ កាប់សម្លាប់ ជំងឺរាតត្បាត គ្រោះទុរ្ភិក្ស ស្លាប់រង្គាល សង្គ្រាមបានអូសបន្លាយអស់ពេល ១០ ឆ្នាំ (1475-1485) ។
- ប្រជារាស្ត្រខ្មែរត្រូវស្លាប់ដោយសង្គ្រាមស៊ីវិលយ៉ាងច្រើន។
- ធ្វើឱ្យបែកបាក់សាមគ្គីភាព
- មិនអាចរំដោះខេត្តភាគខាងលិច
- បាត់បង់ទឹកដីខ្មែរដោយបរទេសឈ្លានពាន
- ត្រូវអាប់ឱនកិត្តិយសក្នុងរាជវង្សខ្មែរ ...។

មេរៀនទី

# ២ បន្ទាយលង្វែក (សតវត្សទី១៦)

## សំណួរ -ចម្លើយ

**១. តើហេតុអ្វីបានជាព្រះបាទចន្ទរាជាកសាងបន្ទាយលង្វែក?**

**ចម្លើយ** បានជាព្រះបាទចន្ទរាជាកសាងបន្ទាយលង្វែក ព្រោះដើម្បី

- ការពារវាយឆ្មក់ពីសត្រូវ
- កសាងរាជធានីឱ្យកាន់តែរឹងមាំ...។

**២. ចូររៀបរាប់ពីស្ថានភាពបន្ទាយលង្វែក?**

**ចម្លើយ** ស្ថានភាពបន្ទាយលង្វែកជាចំណុចយុទ្ធសាស្ត្រមានទន្លេ បឹង និងព្រៃឈើជារបាំង។ បន្ទាយនេះមានរាងបួនជ្រុង បណ្តោយ 3km ទទឹង 2 km កំពែងដីកម្ពស់ 15 ហត្ថ (7.5m) ហ៊ុមព័ទ្ធដោយគូទឹកនិងដាំដើមឫស្សីកំរាស់ 2 សិន (1 សិន = 40m) ព័ទ្ធជុំវិញ។ ក្នុងបន្ទាយលង្វែកមានវាំងស្តេច បន្ទាយទាហាន ផ្ទះស្រីស្នំ 22 រោងដំរី រោងសេះ ប្រាសាទពីរ ជីកស្រះធំ 4 គ្រប់ទិស ហើយចិញ្ចឹមត្រីព្រួល រ៉ស់ ឆ្តោ ព្រោះនៅជាប់មាត់

ទន្លេសាប សង់ឃ្លាំង ១៥ ខ្នងសម្រាប់ស្រូវអង្ករ ត្រីងៀត ត្រីឆ្អើរ ប្រហុក ផ្អក...។ បន្ទាយលង្វែកមានទ្វារធំ 4 នៅទិសទាំង 4 និងទ្វារតូច 4 នៅចំជ្រុងនៃទិសតូចទាំង 4 ។ មានសួនច្បារធំ មានភូមិអ្នកស្រុក 4 មានវត្ត 5 ។

## ៣. តើមូលហេតុអ្វីបានជាមានឈ្មោះថាខេត្តសៀមរាប?

**ចម្លើយ** បានជាមានឈ្មោះថាខេត្តសៀមរាប ព្រោះដោយសារដោយសារសៀមលើកទ័ពមកវាយខ្មែរនៅក្បែរក្រុងអង្គរ ព្រះបាទចន្ទរាជាបានកេណ្ឌទ័ពទៅទប់ទល់នឹងទ័ពសៀមនៅស្ទឹងអង្គរ និងវាយបកសៀមឱ្យបាក់ទ័ពចាប់ជាឈ្លើយសឹងរាបពាន់នាក់។ ត្រង់កន្លែងនោះហៅភូមិសៀមរាប ឃុំសៀមរាប និងស្រុកសៀមរាប ក្លាយទៅជាខេត្តសៀមរាបរហូតដល់សព្វថ្ងៃ (សៀមចាញ់ខ្មែររាប)។

## ៤. តើមូលហេតុអ្វីខ្លះបានជាបែកបាក់បន្ទាយលង្វែក?

**ចម្លើយ** មូលហេតុបានជាបែកបាក់បន្ទាយលង្វែក គឺ

- **ព្រះរាជា** : សត្ថាទី ។ ឆោតល្ងង់ទៅជួយរំដោះក្រុងអយុធ្យារបស់សៀមពីការត្រួតត្រារបស់ភូមា។

- **សៀម** : សៀមរមិលគុណ ប្រើល្បិចបញ្ជូនសង្ឃមកយកការណ៍ក្នុងបន្ទាយ និងប្រើល្បិចបាចប្រាក់ដួងចូលគុម្ពប្ញស្សី ។

- **វិបត្តិផ្ទៃក្នុង** : រាជវង្សានុវង្ស នាម៉ឺនមន្ត្រី ប្រជារាស្ត្រមិនពេញចិត្តនឹងព្រះសត្ថាទី ។ តែងតាំកូនអាយុ ១។ ឆ្នាំឱ្យគ្រងរាជ និង ៦ ឆ្នាំជាមហាឧបរាជ។ ដូចនេះហើយទើបពួកគេបាត់បង់ស្មារតីប្រយុទ្ធ។

- **ប្រជារាស្ត្រខ្មែរ** : ក្រីក្រ ឆោតល្ងង់ ចង់បានប្រាក់ដួងក៏នាំគ្នាកាប់ឆ្ការគុម្ពប្ញស្សីដែលជារបស់ការពារបន្ទាយដ៏រឹងមាំ។

- **សាមគ្គី** : ប្រទេសខ្មែរហាក់ដូចជាបាត់បង់សាមគ្គីភាព ដូចជាសត្ថាទី ។ នាំកូនទាំងពីររត់ភៀសខ្លួនទៅប្រទេសឡាវ ប្រជារាស្ត្រអស់ជំនឿ។

**៩. ក្រោយបែកបន្ទាយលង្វែក តើប្រទេសកម្ពុជាមានស្ថានភាពដូចម្ដេច?**

**ចម្លើយ** ក្រោយបែកបន្ទាយលង្វែក ប្រទេសកម្ពុជាមានស្ថានភាព ដូចខាងក្រោម :

- ប្រទេសជាតិអស់ឫទ្ធានុភាព ធ្លាក់ជារដ្ឋទន់ខ្សោយនៅអាស៊ីអាគ្នេយ៍
- ខ្មែរបាត់បង់កេតនភណ្ឌជាតិ ក្បួន ច្បាប់ អ្នកប្រាជ្ញ បណ្ឌិត និងវប្បធម៌ ត្រូវសៀមឆក់ប្លន់អស់ ។
- ប្រទេសធ្លាក់ក្នុងភាពអនាធិបតេយ្យគ្រោះទុរ្ភិក្ស ពេញប្រទេស
- ព្រះរាជវង្សានុវង្សប្រព្រឹត្តអំពើពាលាលែងមានឫទ្ធានុភាព
- ប្រជារាស្ត្រអស់ជំនឿលើព្រះរាជា
- ប្រទេសកម្ពុជាបាត់បង់ខេត្ត ចន្ទបុរី បស្ទឹមបុរី នគររាជសីមា បាត់ដំបង សៀមរាប ពោធិ៍សាត់ ។

---

## មេរៀនទី

## ៣ សម័យឧដុង្គ ( ១៦២០-១៨៦៣)

### សំណួរ-ចម្លើយ

**១. តើនយោបាយបោះបង់ទំនាក់ទំនងជាមួយសៀម របស់ស្ដេចស្រីសុរិយោពណ៌បានផលចំណេញអ្វីខ្លះ សម្រាប់ប្រទេសខ្មែរនៅសម័យនោះ?**

**ចម្លើយ** នយោបាយបោះបង់ទំនាក់ទំនងជាមួយសៀម របស់ស្ដេចស្រីសុរិយោពណ៌បានផលចំណេញសម្រាប់ប្រទេសខ្មែរនៅសម័យនោះ ដូចជា :

- មិនបាច់រណាបនឹងសៀម
- មិនបាច់នាំសួយសាអាករទៅឱ្យសៀម
- មិនបាច់បង់ទឹកដីនៅភាគខាងលិច ។

**២. ចូររៀបរាប់ពីព្រឹត្តការណ៍នៅក្នុងរជ្ជកាលព្រះបាទអង្គចន្ទ ។**

**ចម្លើយ** ព្រឹត្តការណ៍នៅក្នុងរជ្ជកាលព្រះបាទអង្គចន្ទ គឺ

- ព្រះអង្គចន្ទជាបុត្រអង្គអេងត្រូវព្រះចៅសៀមលើកឱ្យឡើងសោយរាជ្យនៅបឹងកកនៅក្នុងព្រះជន្ម ១៦ វស្សា ដោយមានក្សត្រអង្គស្ងួនជាព្រះឧភយោរាជនិងអង្គអិមជាព្រះឧបរាជ។
- ក្រោយមកមានរឿងវិវាទមួយរវាងអង្គចន្ទនឹងអង្គស្ងួន ទើបអង្គចន្ទហៅទ័ពយួនឱ្យមកបោះទីតាំងនៅកោះចិន ដើម្បីការពារ។
- ចាប់ពីពេលនោះមកខ្មែរក្លាយខ្លួនជាចំណុះយួន ហើយនាំសួយសារអាករថ្វាយស្តេចយួនចំនួនបីឆ្នាំជាប់គ្នា។
- ដោយក្លាយក្រែងខ្មែរធ្លាក់ក្នុងអាណានិគមយួនផ្តាច់មុខ សៀមមិនបង្អង់ក៏លើកទ័ពជាបីផ្នែកចូលមកវាយទ័ពខ្មែរ-យួន។ លក្ខខណ្ឌនេះតម្រូវឱ្យខ្មែរលើកសួយសារអាករថ្វាយស្តេចសៀមទើបសៀមព្រមដកទ័ពចេញពីប្រទេសខ្មែរ។
- នៅឆ្នាំ ១៨១៤ សៀមលើកទ័ពមកសង្គ្រប់យកខេត្តមូលព្រៃ ទន្លេពៅ និងស្ទឹងត្រែង។
- នៅឆ្នាំ ១៨១៥ បានគេកេណ្ឌប្រជាជនខ្មែរចំនួន ៥០០០ នាក់ឱ្យជីកព្រែកវិញតេឬព្រែកយួន នៅលើទឹកដីខេត្តមាត់ជ្រូក មាន

បណ្តោយ 53 km ទទឹង 33m ជម្រៅ 2.50m ដែលតភ្ជាប់ពីមាត់ជ្រូកទៅសមុទ្រត្រង់ពាម ( ហាទៀង ) និងព្រែកវិញអានប្រវែង 14km ភ្ជាប់ពីទន្លេធំទៅទន្លេតូច ( ទន្លេបាសាក់ ) ។

- ព្រះឧទ័យរាជាអង្គចន្ទទ្រង់សុគតនៅឆ្នាំ 1834 ដោយរោគាពាធក្នុងព្រះជន្ម 44 វស្សានៅក្រុងឧដុង្គ ។

---



## មេរៀនទី

## ៤ អរិយធម៌ខ្មែរក្រោយសម័យអង្គរ

### សំណួរ -ចម្លើយ

**១. ហេតុអ្វីបានជាព្រះបាទពញាយ៉ាតប្តូររាជធានីពីអង្គរមក ចតុមុខ?**

**ចម្លើយ** បានជាព្រះបាទពញាយ៉ាតប្តូររាជធានីពីអង្គរមកចតុមុខ ព្រោះដើម្បី :

- ការពារខ្លួនពីសំណាក់សត្រូវសៀម ។
- នៅចតុមុខមានទីតាំងល្អ សម្រាប់ស្តារជីវភាពប្រជារាស្ត្រ ដែលបានធ្លាក់ចុះយ៉ាងគំហុកដោយសារសៀមចូលឈ្លានពាន ជាច្រើនសា ។
- នៅតំបន់អង្គរចំនួនប្រជាជនចុះខ្សោយ ចំណែកភាគខាងត្បូង មានចំនួនប្រជាជនច្រើនជាងដែលងាយស្រួលក្នុងការប្រមូល កម្លាំងប្រជាជន និងកសាងប្រទេសជាតិ ។
- ដីមានជីជាតិងាយស្រួលក្នុងការបង្កបង្កើនផល ។

- នៅតំបន់ចតុមុខងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មទាំងផ្លូវគោក និងផ្លូវទឹក។ រីឯតំបន់អង្គរត្រូវពួកសៀមបំផ្លិចបំផ្លាញអស់នូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។

សរុបមក កត្តាដូចបានរៀបរាប់ខាងលើនេះហើយ ដែលនាំឱ្យព្រះបាទពញាយ៉ាតប្តូររាជធានីពីអង្គរមកចតុមុខ។

**២. តើការជ្រើសតាំងស្តេចថ្មីឱ្យឡើងសោយរាជ្យ ត្រូវប្រព្រឹត្តឡើងដូចម្តេចខ្លះ?**

<u>**ចម្លើយ**</u>

ការជ្រើសតាំងព្រះរាជាថ្មីប្រព្រឹត្តទៅតាមប្រពៃណីគឺយកតែរាជបុត្រច្បង បុត្របន្ទាប់ជ្រើសតាំងជាឧបរាជ ជួនកាលព្រះរាជាដែលដាក់រាជ្យឱ្យបុត្រមានតួនាទីជាឧភយោរាជ សម្រាប់ធ្វើជាប្រឹក្សា ព្រោះស្តេចដែលសោយរាជ្យមានវ័យក្មេងពេក។

**៣. ចូរប្អូនពន្យល់ពីបុព្វហេតុសំខាន់ៗ ដែលនាំឱ្យកើតសង្គ្រាមក្រោយរជ្ជកាលព្រះបាទពញាយ៉ាត។**

**ចម្លើយ** បុព្វហេតុសំខាន់ៗ ដែលនាំឱ្យកើតសង្គ្រាមក្រោយរជ្ជកាលព្រះបាទពញាយ៉ាត គឺ

- បុត្រព្រះបាទពញាយ៉ាតច្បាំងគ្នាដណ្តើមរាជបល្ល័ង្ក ។
- នៅពេលបុត្រច្បងពញាយ៉ាតនាមនរាយណ៍រាជាសោយទិវង្គតទៅ សង្គ្រាមបានផ្ទុះឡើងដែលបង្កដោយបុត្រនរាយណ៍រាជានាមស្រីសុរិយោទ័យ បាននាំប្រជារាស្ត្របះបោរប្រឆាំងនឹងធម្មរាជា ព្រោះខូចចិត្តមិនបានសោយរាជ្យ ។
- ក្នុងឆ្នាំ 1586 ព្រះសត្ថាទី ១ ដោយខ្លាចក្រែងរាជសម្បត្តិបន្តពីព្រះអង្គធ្លាក់ទៅក្នុងដៃស្រីសុរិយោពណ៌ជាប្អូន ក៏បានរៀបអភិសេកឱ្យបុត្រពីរអង្គគឺជ័យជេដ្ឋាមានព្រះជន្ម ១១ ព្រះវស្សាឡើងសោយរាជ្យនិងពញាតន់ព្រះជន្ម៦ ព្រះវស្សាជាឧបរាជ ។ ជាឱកាសឱ្យសៀមលើកទ័ពមកវាយខ្មែរជាលើកទីពីរនៅឆ្នាំ 1594 ។
- នៅឆ្នាំ 1600 ពញាញោមដែលជាបុត្រចុងក្រោយរបស់ព្រះសត្ថាទី ១ ជាស្តេចគ្មានទសពិធរាជធម៌ ឆ្កួតនឹងល្បែងភ្នាល់ដាក់ប្រាក់និងប្រព្រឹត្តអំពើធនាចារ ។ ដោយអត់ទ្រាំពុំបាន

រាជ្យវង្សានុវង្សក៏ផ្ញើសារទៅព្រះចៅសៀមសុំយាងក្សត្រស្រី ស៊ីសុរិយោពណ៌ ដែលកំពុងជាប់ជាឈ្លើយសឹកឱ្យត្រឡប់មក សោយរាជ្យដើម្បីជាម្លប់សម្រាប់ប្រជារាស្ត្រខ្មែរជន្មសពញា ញោម ។

**៤. តាមប្រពៃណីនៃច្បាប់តំណរាជ្យបានបញ្ញត្តិតឹងរ៉ឹងបំផុត ចំពោះស្តេចជាស្ត្រី តើមានទស្សនៈជំទាស់អ្វីខ្លះ? ចូរពន្យល់ឱ្យបានក្បោះក្បាយព្រមទាំង លើកឧទាហរណ៍ក្នុងមេរៀនមកបញ្ជាក់ផង ។**

__**ចម្លើយ**__ ចំពោះស្តេចជាស្ត្រី មានទស្សនៈជំទាស់ ដូចខាងក្រោម :

- ទស្សនៈដែលទំទាស់មិនឱ្យស្ត្រីឡើងសោយរាជ្យដោយសំអាងថា បើតាមប្រពៃណីនៃការដោយរាជ្យតាំងពីដើមរហូតមកបាននិយាយថា បើស្តេចអង្គណាមួយក្រោយពេលសុគតពុំមានបុត្រាសោយរាជ្យបន្តនោះ គេមិនអាចយកក្សត្រីឱ្យឡើងសោយរាជ្យឡើងយតីគេត្រូវជ្រើសរើសក្នុងចំណោមពូកបាតូ ។
- ទស្សនមួយទៀតបានពោលថាបើកាលណាស្តេចគ្មានបុត្រាសោយរាជ្យ

គេត្រូវរើសក្សត្រាអង្គណាមួយដែលមានសាច់ឈាមស្ដេចគ្រងរាជ្យឱ្យស្នងរាជ្យបន្ត។ ឧទាហរណ៍ នៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាមានស្ត្រីតែម្នាក់គត់ដែលបានសោយរាជ្យនៅសម័យអាណាចក្រភ្នំ។ ប៉ុន្តែសម័យក្រោយៗមកទៀត ដែលមានរយៈកាលរាប់ពាន់ឆ្នាំ គេពុំឃើញមានស្ត្រីត្រូវបានជ្រើសតាំងឱ្យសោយរាជ្យឡើយ។ នៅសម័យឧដុង្គក្រោយពីព្រះបាទអង្គចន្ទសោយទិវង្គតនៅក្នុងឆ្នាំ 1834 ដោយពុំមានបុត្រាមានតែបុត្រី (បីព្រះអង្គ) ជាការពិបាកបំផុតក្នុងការជ្រើសតាំងព្រះរាជាមួយអង្គឱ្យស្នងរាជ្យ។

**៥. នៅក្នុងរជ្ជកាលព្រះអង្គឌួងមានការបែងចែករដ្ឋបាលដូចម្ដេចខ្លះ?**

**ចម្លើយ**

នៅក្នុងរជ្ជកាលព្រះអង្គឌួងខេត្តខ្មែរមានទាំងអស់ចំនួន 40 បែងចែកជាពីរប្រភេទ គឺតូចនិងធំ ដែលខេត្តធំគ្រប់គ្រងដោយចៅហ្វាយស្រុក (ខេត្ត) ដែលជ្រើសតាំងដោយព្រះរាជា ចំណែកខេត្តតូចគ្រប់គ្រងដោយចៅមឿង ជ្រើសតាំងដោយចៅហ្វាយស្រុក។ ប៉ុន្តែស្រុកខ្លះមានទឹកដីធំពេកនាំឱ្យពិបាកក្នុងការគ្រប់

គ្រង ទើបព្រះរាជាទ្រង់ត្រាស់បង្គាប់ឱ្យបែងចែកប្រទេសជា ៥២ ស្រុកវិញ ដែលមានទំហំប្រហាក់ប្រហែលគ្នា ហើយចាប់ពីពេលនោះមកងារចៅមឿងត្រូវចោលលែងប្រើ ។

**៦. ចូរពន្យល់ពីលក្ខណៈសំខាន់ក្នុងការប្រើសត្វពាហនៈក្នុងវិស័យកងទ័ព ។**

**ចម្លើយ** លក្ខណៈសំខាន់ៗក្នុងការប្រើសត្វពាហនៈក្នុងវិស័យកងទ័ព គឺ

- ការប្រើដំរីជាសត្វមានមាឌធំងាយស្រួលក្នុងការដឹកជញ្ជូន ។
- ទ័ពខ្មែរប្រើដំរីតាំងពីសម័យចក្រភពអង្គរមកម្ល៉េះ ព្រោះមានការបង្ហាញនៅតាមចម្លាក់នៅប្រាសាទបាយ័នជាពីងតាង ។
- នៅឆ្នាំ១៨៤៥ ទ័ពខ្មែរនិងសៀមបានទប់ទល់ការវាយលុកទ័ពយួនមានប្រសិទ្ធភាពដោយការប្រើដំរី ។
- ក្នុងរជ្ជកាលព្រះបាទនរោត្តម អ្នកទទួលខុសត្រូវខាងដំរីហៅថា នុក្កូល ដែលស្ថិតនៅក្រោមក្រសួងកងទ័ព ។ មន្ត្រីនេះមានភារកិច្ចគង្វាលដំរី ថែទាំឱ្យចំរើន ទាក់ដំរីព្រៃបន្ថែម និងបង្ហាត់ដំរីឱ្យចេះប្រយុទ្ធក្នុងពេលសង្គ្រាម ។

- ពួកព្រាហ្មណ៍ ៖ ទាក់ជាអ្នកបង្ហាត់ដំរីនិងទាហានសម្រាប់កង ដំរីមុននិងធ្វើសង្គ្រាម ។
- ទ័ពសេះមានពីរប្រភេទ គឺរទេះសេះនិងរទេះគោ។

**៧. តើសង្គមខ្មែរសម័យសក្តិភូមិ គេចែកសង្គមមនុស្សជាស្រទាប់វណ្ណៈអ្វីខ្លះ?**

**ចម្លើយ** សង្គមខ្មែរសម័យសក្តិភូមិ គេចែកសង្គមមនុស្សជាស្រទាប់វណ្ណៈគឺ មន្ត្រី ប្រជារាស្ត្រ និងពួកទាសករ ។

**៨. តើវណ្ណៈទាសករមានប៉ុន្មានប្រភេទ? អ្វីខ្លះ?**

**ចម្លើយ** វណ្ណៈទាសករមាន ៣ ប្រភេទ គឺ

- ពួកអ្នកងារទាំងអស់សុទ្ធតែជាទាសករ ដូចជា ពលកម្លោះមហាត នៅបម្រើព្រះរាជាដូចជា ឃ្វាលដំរី ធ្វើស្រែ ចាំឃ្លាំងបុកអង្ករ ។ ពួកគេជាទាសករបន្តពីឪពុករហូតដល់កូនចៅ ។
- ពួកទាសករ ហៅថាខ្ញុំ គឺជាអ្នកជំពាក់បំណុលគេដោយប្រគល់ខ្លួនឱ្យម្ចាស់បំណុល ។ ពួកគេអាចលោះខ្លួនបានប្រសិនមាន

អ្នកធានាយកប្រាក់មកលោះបំណុល ។ កូនបំណុលគ្មានប្រាក់លោះក្លាយជាទាសករអស់មួយជីវិត ឬ តពូជទៀតផង ។

- ទាសករម្យ៉ាងទៀតគឺបានមកពីការទិញ ឬត្រូវគេចាប់យកមកលក់សម្រាប់មុខរបរពាណិជ្ជកម្ម ដូចជាពួកទាសករស្បែកខ្មៅនៅសហរដ្ឋអាមេរិកនៅសតវត្សទី ១៥ ។ ពួកទាំងនេះមានពួកព្នង លាវ រដែ គួយ ព័រ ។

---

## ?សំណួរបញ្ចប់ជំពូកទី២

I. *ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ*

១. តើព្រះបាទពញាយ៉ាតមកតាំងរាជធានីនៅចតុមុខមង្គល នៅឆ្នាំណា?

☑ក. 1431 ☐ខ. 1432

☐គ. 1433 ☐ឃ. 1434

២. តើបន្ទាយលង្វែកកសាងឡើងដោយស្នាព្រះហស្តព្រះរាជាអង្គណា?

☑ក. ចន្ទរាជា ☐ខ. បរមេន្ទរាជា

☐គ. សត្ថាទី១ ☐ឃ. ស្រីយុរិយោពណ៌

៣. តើព្រះរាជាអង្គណាមកតាំងរាជធានីនៅឧដុង្គដំបូងគេ?

☑ក. ស្រីយុរិយោពណ៌ ☐ខ. ជ័យជេដ្ឋាទី2 -

☐គ. អង្គចន្ទ ☐ឃ. អង្គអេង

៤. តើព្រះរាជាអង្គណាដែលបានស្តារវប្បធមិនិងប្រទេសខ្មែរឱ្យខ្ពង់ខ្ពស់ឡើងវិញ?

☐ក. អង្គម៉ី ☑ខ. អង្គឌួង

☐គ. នរោត្តម ☐ឃ. អង្គអីម

៥. តើព្រះរាជាអង្គណាដែលក្បត់ចូលដៃជាមួយសៀម ដើម្បីដណ្ដើមរាជតែអង្គឯង?

☐ក. ព្រះស្រីរាជា ☐ខ. នរាយណ៍រាជា

☑គ. ធម្មរាជា ☐ឃ. ស្រីសុរិយោទ័យ

II. *ចូរជ្រើសរើសពាក្យ ,កន្សោមពាក្យឆ្នាំ ឬ ឈ្មោះទៅបំពេញឈ្មោះខាងក្រោម*

(3អង្គ , វាយខ្មែរ , វិញតេ , 1575 , វិញអានសៀមនិងយួន)

១. នៅឆ្នាំ 1847 ដើម្បីបញ្ចប់ទង្វើរបស់ ...***សៀម***... និង ...***យួន***... ព្រះអង្គបានអំពាវនាវរកជំនួយពីបារាំង ។

២. ព្រះបាទពញាយ៉ាតមានអ្នកម្នាង ... 3... អង្គនិងបុត្រ ....3... អង្គ ។

៣. នៅឆ្នាំ..1575..ព្រះបាទស្រីរាជាសម្រេចព្រះទ័យនឹងវាយរំដោះខេត្តខាងលិចពីសៀមវិញ ។

៤. នៅឆ្នាំ 1530 ស្តេចសៀមបញ្ជាពញាអុងលើកទ័ព ១០០០០ នាក់មក ...***វាយខ្មែរ***...។

៥. នៅឆ្នាំ 1815 យួនកេណ្ឌប្រជាជនខ្មែរចំនួន 5000 នាក់ឱ្យជីកព្រែកពីរគឺ ...***វិញអាន***... និង ...***វិញតេ***...។

III. *ចូរគូសភ្ជាប់ ឬ ផ្គូផ្គងពីព្រះនាមព្រះរាជាទៅសម័យកាលដែលព្រះអង្គគ្រងរាជ្យ*

| នាមព្រះរាជា | សម័យកាល | ចម្លើយ |
|---|---|---|
| ១. អង្គឌួង | ក. សម័យចតុមុខ | ១. → គ |
| ២. ពញាយ៉ាត | ខ. សម័យលង្វែក | ២. → ក |
| ៣. ចន្ទរាជា | គ. សម័យឧដុង្គ | ៣. → ខ |

**IV. សំណួរត្រិះរិះ**

**១. តើហេតុអ្វីបានជាព្រះបាទពញាយ៉ាតជ្រើសរើសយកចតុមុខជារាជធានី?**

**ចម្លើយ** បានជាព្រះបាទពញាយ៉ាតប្តូររាជធានីពីអង្គរមកចតុមុខ ព្រោះដើម្បី :

- ការពារខ្លួនពីសំណាក់សត្រូវសៀម ។
- នៅចតុមុខមានទីតាំងល្អ សម្រាប់ស្តារជីវភាពប្រជារាស្ត្រដែលបានធ្លាក់ចុះយ៉ាងគំហុកដោយសារសៀមចូលឈ្លានពានជាច្រើនសា ។
- ភាគខាងត្បូង មានចំនួនប្រជាជនច្រើនជាងដែលងាយស្រួលក្នុងការប្រមូលកម្លាំងប្រជាជន និងកសាងប្រទេសជាតិ ។
- ដីមានជីជាតិងាយស្រួលក្នុងការបង្កបង្កើនផល ។
- នៅតំបន់ចតុមុខងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មទាំងផ្លូវគោក និងផ្លូវទឹក ។

**២. តើហេតុអ្វីបានជាព្រះបាទអង្គឌួងសម្រេចព្រះទ័យទៅពឹងបារាំង?**

**<u>ចម្លើយ</u>** បានជាព្រះបាទអង្គឌួងសម្រេចព្រះទ័យទៅពឹងបារាំង ព្រោះដើម្បីជួយស្រោចស្រង់ប្រទេសខ្មែរឱ្យផុតពីការលេបត្របាក់របស់យួននិងសៀម ។

**៣. អរិយធម៌នៅសម័យក្រោយអង្គរមានកម្រិតដូចម្តេច បើប្រៀបធៀបទៅនឹងសម័យអង្គរ? ព្រោះអ្វី?**

**ចម្លើយ** អរិយធម៌នៅសម័យក្រោយអង្គរមានកម្រិតទាបណាស់ បើប្រៀបធៀបទៅនឹងសម័យអង្គរ ព្រោះនៅសម័យនោះ ប្រទេសខ្មែរយើងបានជួបវិបត្តិសង្គ្រាមក្នុងស្រុក និងសង្គ្រាមឈ្លានពានពីប្រទេសជិតខាង ហើយមិនបានកសាងអ្វីឱ្យបានធំដុំជាគោលនៃអរិយធម៌ឡើយ។ ចំណែកសម័យអង្គរវិញប្រទេសខ្មែរមានសន្តិភាពខ្មែរបានកសាងនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងបានកសាងប្រាសាទសិលានិងសិលាចារឹកជាច្រើនដែលបន្សល់ទុករហូតដល់សម័យបច្ចុប្បន្ននេះ។

**៤. តើការដួលរលំបន្ទាយលង្វែកជះឥទ្ធិពលអ្វីខ្លះ ទៅលើវិស័យវប្បធម៌?**

**ចម្លើយ** ការដួលរលំបន្ទាយលង្វែកជះឥទ្ធិពលទៅលើវិស័យវប្បធម៌ដូចជា :

ការបែកបាក់បន្ទាយលង្វែក ជាហេតុញ៉ាំងប្រទេសខ្មែរឱ្យអស់ឫទ្ធានុភាព ធ្លាក់ខ្លួនជារដ្ឋតូចតាចនៅភូមិភាគអាស៊ីអាគ្នេយ៍។ ការបែងបាក់បន្ទាយលង្វែកបានធ្វើឱ្យខ្មែរយើងបាត់បង់អស់ក្បួន

ខ្មាត អ្នកប្រាជ្ញបរទេសក៏ធ្វើដែលត្រូវខ្លាំងគៀរយកទៅស្រុកវា។ ម្យ៉ាងវិញទៀត ខ្មែរយើងត្រូវភ្លេចនូវអ្វីជារបស់ខ្មែរ ហើយបែរជាទទួលយកមកពីសៀមវិញ។

**៥. តើហេតុអ្វីបានជាសម័យក្រោយអង្គរពលរដ្ឋខ្មែរ គោរពបូជាព្រះពុទ្ធសាសនា? ចូរពន្យល់។**

**ចម្លើយ** បានជាសម័យក្រោយអង្គរពលរដ្ឋខ្មែរ គោរពបូជាព្រះពុទ្ធសាសនា ព្រោះចាប់ពីបដិវត្តន៍នាយត្រសក់ផ្អែមព្រះពុទ្ធសាសនាបានចាក់ឫសគល់យ៉ាងជ្រៅចូលក្នុងសង្គមខ្មែរ ជនជាតិខ្មែរគ្រប់ស្រទាប់ ចាប់តាំងពីព្រះមហាក្សត្រដល់ប្រជារាស្ត្រតូចតាចបំផុតសុទ្ធតែមានជំនឿមុតមាំលើព្រះពុទ្ធសាសនាដែលបានចាត់ទុកថាជាទីពឹងទីរលឹក ទោះបីគេបានលះបង់ចោលជំនឿដើមរបស់គេលើខ្មោច បិសាច អារក្ស អ្នកតា បង់បត់ក៏ដោយ។

**៦. តើហេតុអ្វីបានជាបុព្វបុរសខ្មែរកសាងប្រាសាទ និងចារឹកអក្សរលើសិលា?**

**ចម្លើយ** បានជាបុព្វបុរសខ្មែរកសាងប្រាសាទ និងចារឹកអក្សរលើ

សិលា ពីព្រោះ ៖

**ក. ការកសាងប្រាសាទ**

- ដើម្បីបង្ហាញពីមហិទ្ធិរិទ្ធិរបស់ព្រះរាជា
- បន្សល់ទុកសម្រាប់មនុស្សជំនាន់ក្រោយ
- ដើម្បីជាយុទ្ធសាស្ត្រក្នុងការការពារសត្រូវ
- ជាទម្លាប់តៗគ្នារបស់ព្រះមហាក្សត្រខ្មែរ

**ខ. ចារឹកអក្សរលើសិលា**

- ទុកបានរយៈពេលយូរ
- បង្ហាញពីភាពអំណាត់របស់បុព្វបុរសខ្មែរ
- ទុកជាព័ត៌មានសម្រាប់មនុស្សជំនាន់ក្រោយ
- សម័យនោះពុំទាន់មានក្រដាស . . .។

**៧. ចូរពន្យល់ពីប្រវត្តិរឿងភ្នំដូនពេញ។**

**ចម្លើយ** ប្រវត្តិរឿងភ្នំដូនពេញ គឺ

មានស្ត្រីម្នាក់មេម៉ាយអ្នកមានស្តុកស្តម្ភម្នាក់ អ្នកផលងហៅថាដូនពេញបានឱ្យគេលើកដីពូនជាកូនភ្នំ សាងសង់ព្រះវិហារដើម្បីតម្កល់ព្រះពុទ្ធរូប 4 អង្គ ធ្វើអំពីលង្ហិន និងបដិមាថ្មមួយអង្គស្ថិត

ក្នុងដើមគគីរមួយ ដែលបានរសាត់អណ្តែតតាមទឹកទន្លេមេគង្គ។ យាយពេញសង់ព្រះវិហាររួចរាល់នៅឆ្នាំ 1372 បដិមាថ្មនោះឈ្មោះថាអ្នកតាព្រះចៅ តែឥឡូវគេហៅលោកតាព្រះចៅវិញ។

**៨. ទស្សនៈមួយលើកឡើងថា ព្រះបាទស្រីសុគន្ធបទក្ស័យព្រះជន្មដោយសារស្រី។ តើទស្សនៈនេះមានអត្ថន័យបែបណា? ចូរប្អូនធ្វើការបកស្រាយ។**

**ចម្លើយ** ទស្សនៈមួយលើកឡើងថា ព្រះបាទស្រីសុគន្ធបទក្ស័យព្រះជន្មដោយសារស្រី។ ទស្សនៈនេះមានន័យថា :

ដោយសារព្រះបាទស្រីសុគន្ធបទពេញចិត្តនឹងនាងពៅ ហើយតែងតាំងធ្វើជាស្នំឯក។ ព្រះអង្គតែងតាំងនាយកន (ប្អូនប្រុសនាងពៅ) ជាមហាតលិក។ នៅឆ្នាំ 1509 ស្រីសុគន្ធបទយល់សុបិនឃើញនាគរាជដ៏ធំមកយាយីព្រះអង្គនិងស្វេតច្ឆត្រ ហោរាទស្សន៍ទាយចំលើនាយកន (ឆ្នាំរោង) ព្រះអង្គក៏បញ្ជាឱ្យគេបបួលនាយកនទៅបង់សំណាញ់ក្នុងល្បិចសម្លាប់។ ប៉ុន្តែនាងពៅស្តាប់ឮក៏យកដំណើងទៅប្រាប់ប្អូនកន ហើយនាយកនក៏គេចរួចពីល្បិចនេះ។ លុះក្រោយមកនាយកនក៏ងើបបះបោរ និងសម្លាប់

ព្រះបាទស្រីសុគន្ធបទទៅ។ ដោយមូលហេតុនេះហើយទើបគេថា ស្រីសុគន្ធបទក្បាលព្រះជន្មដោយសារស្រី។

**៩. ចូរពន្យល់យុទ្ធសាស្ត្រនៃបន្ទាយលង្វែក។**

**ចម្លើយ**

ការជ្រើសរើសយកបន្ទាយលង្វែក ដើម្បីជាទីតាំងរាជធានីថ្មីនេះ គឺព្រះចន្ទរាជា ទ្រង់ឈ្វេងយល់ថា កន្លែងនោះជាចំណុចយុទ្ធសាស្ត្រមួយស្រួលការពារខ្លួន ព្រោះនៅជិតនោះមានទន្លេ មានបឹង និងមានព្រៃទៀតផង បន្ទាយនេះមានរាងបួនជ្រុងទ្រវែងទទឹងមានប្រវែង 2 គ.ម ឯបណ្តោយមានប្រវែងជិត 3 គ.ម មានកំពែងដី គូទឹក និងរបងឫស្សីកំរាស់ពីរសិន (160ម) ព័ទ្ធជុំវិញ។

## ជំពូកទី៣ ប្រវត្តិសាស្ត្រតំបន់និងអាស៊ីប៉ាស៊ីភិច

## មេរៀនទី

## ១ ប្រទេសឥណ្ឌូនេស៊ី

### សំណួរ -ចម្លើយ

**១. តើប្រទេសឥណ្ឌូនេស៊ីធ្លាប់នៅក្រោមអាណានិគមរបស់ប្រទេសណាខ្លះ?**

**ចម្លើយ** ប្រទេសឥណ្ឌូនេស៊ីធ្លាប់នៅក្រោមអាណានិគមរបស់ប្រទេសហូឡង់ ជប៉ុន ។

**២. តើគេចែកនយោបាយរបស់លោកស៊ូកាណូជាប៉ុន្មានដំណាក់កាល? គឺអ្វីខ្លះ?**

**ចម្លើយ** គេចែកនយោបាយរបស់លោកស៊ូកាណូជា 2ដំណាក់កាលគឺ

- ដំណាក់កាលទី I គឺលទ្ធិប្រជាធិបតេយ្យអាស្រ័យសភា តាមបែបលោកខាងលិច (1945-1959) ។
- ដំណាក់កាលទី 2 គឺប្រជាធិបតេយ្យដឹកនាំពួកយោធា (1959-

1965) ។

**៣. តើប្រទេសឥណ្ឌូនេស៊ីបានប្រកាសឯករាជ្យប៉ុន្មានលើក? នៅឆ្នាំណាខ្លះ? ពីព្រោះអ្វី?**

**ចម្លើយ** ប្រទេសឥណ្ឌូនេស៊ីបានប្រកាសឯករាជ្យ 2 លើក ។

- **លើកទី1 នៅថ្ងៃទី 24 ខែសីហា ឆ្នាំ** 1945 គឺក្រោយពេលជប៉ុនដាក់អាវុធចុះចាញ់សង្គ្រាមលោកលើកទី2 ។ នៅពេលនេះ ឥណ្ឌូនេស៊ីប្រកាសឯករាជ្យពីជប៉ុន ។
- **លើកទី 2 នៅថ្ងៃទី 17 ខែសីហា ឆ្នាំ** 1950 ។ នៅពេលនេះប្រកាសឯករាជ្យពីប្រទេសហូឡង់ ដែលនៅពេលជប៉ុនចុះចាញ់សង្គ្រាមលោកហូឡង់បានត្រឡប់មកប្រទេសឥណ្ឌូនេស៊ី ។

**៤. ដើម្បីកសាងប្រទេស តើឥណ្ឌូនេស៊ីពឹងផ្អែកលើវិស័យអ្វីខ្លះ?**

**ចម្លើយ** ដើម្បីកសាងប្រទេសឥណ្ឌូនេស៊ីពឹងផ្អែកលើ វិស័យកសិកម្ម ព្រៃឈើ និងឧស្សាហកម្ម ។

---

## មេរៀនទី

## ២ ប្រទេសម៉ាឡេស៊ី

### សំណួរ-ចម្លើយ

**១. តើប្រទេសម៉ាឡេស៊ីមានប៉ុន្មានផ្នែក? គឺអ្វីខ្លះ?**

**ចម្លើយ** ប្រទេសម៉ាឡេស៊ីមាន 2 ផ្នែក គឺ

- ម៉ាឡេស៊ីខាងលិច
- ម៉ាឡេស៊ីខាងកើត ។

**២. តើមានជនជាតិអ្វីខ្លះរស់នៅក្នុងប្រទេសម៉ាឡេស៊ី? តើជនជាតិនីមួយៗ បានបង្កើតអ្វីខ្លះដើម្បីសំគាល់នូវអត្តសញ្ញាណរបស់គេ?**

**ចម្លើយ** ជនជាតិដែលរស់នៅក្នុងប្រទេសម៉ាឡេស៊ីមាន :

- ជនជាតិម៉ាឡេស៊ី 53%
- ជនជាតិចិន 36%
- ជនជាតិឥណ្ឌា 11%

\+ **ដើម្បីសំគាល់អត្តសញ្ញាណរបស់ខ្លួនជនជាតិនីមួយៗ មាន :**

- **ជនជាតិចិន** : រៀនភាសាចិននិងអង់គ្លេស ភាគច្រើនធ្វើការ នៅក្នុងក្រសួងផ្សេងៗនិងជាពាណិជ្ជករនៅតាមទីក្រុង។
- **ជនជាតិឥណ្ឌា** : រៀនភាសាឥណ្ឌានៅតាមសាលារៀន និងជាអ្នកប្រកាន់ជំនឿហិណ្ឌូសាសនា។
- **ជនជាតិម៉ាឡេស៊ី** : ជាម្ចាស់ស្រុក រៀនសូត្រភាសាម៉ាឡេស៊ី ហៅបាហាសាដែលប្រកាន់ជំនឿឥស្លាមសាសនា។

៣. **តើអ្នកណាជាអ្នកបង្កើតសហព័ន្ធម៉ាឡេស៊ី? ហើយសហព័ន្ធនេះជួបឧបសគ្គអ្វីខ្លះ? និងទទួលឯករាជ្យនៅឆ្នាំណា?**

**ចម្លើយ**

+ អ្នកបង្កើតសហព័ន្ធម៉ាឡេស៊ីគឺលោក **ទូន អាប់ឌុលរ៉ាម៉ាន់**។
+ **សហព័ន្ធនេះជួបឧបសគ្គ** : ដោយសារសហគមន៍នីមួយៗសុទ្ធតែមានអត្តសញ្ញាណរៀងៗខ្លួនដូចជា អំបូរ ភាសា អក្សរ និង សាសនាជាដើមហើយសុទ្ធតែអះអាងនូវមោទនភាពរៀងៗខ្លួន។
+ ទទួលបានឯករាជ្យនៅឆ្នាំ 1957។

៤. **តើកត្តាអ្វីខ្លះ ជំរុញសេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ីឱ្យមានការលូតលាស់?**

**ចម្លើយ** កត្តាដែលជំរុញសេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ីឱ្យមានការលូតលាស់ គឺ

- កាត់បន្ថយភាពក្រីក្រជាពិសេសពួកកសិករនៅតាមជនបទ។
- កាត់បន្ថយគំលាតសេដ្ឋកិច្ចរវាងជនជាតិនីមួយៗនៅក្នុងសហព័ន្ធ។
- រដ្ឋាភិបាលបានផ្តល់ទុនវិនិយោគទៅលើវិស័យពាណិជ្ជកម្មកសិកម្មក្នុងស្រុក។
- រដ្ឋាភិបាលបានលើកកម្ពស់វិស័យអប់រំ ក្នុងទិសដៅឱ្យពួកជនបទមានលទ្ធភាពរៀនមុខវិជ្ជា វិជ្ជាជីវៈផ្សេងៗ ដើម្បីឱ្យពួកគេចេញទៅបម្រើការងារនៅតាមផ្នែកឯកជននិងសាធារណៈរបស់រដ្ឋ។
- ធនធានធម្មជាតិក្រោមដី ប្រទេសម៉ាឡេស៊ីមានសំណល់ប្រេងកាត ឧស្ម័នធម្មជាតិ ទង់ដែង បុកស៊ីត ដែលជាអ្នកផ្គត់ផ្គង់ដ៏សំខាន់លើទីផ្សារពិភពលោកផងដែរ។
- វិស័យឧស្សាហកម្មមានគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចវាយនភ័ណ្ឌ។ ចំណែករោងចក្រផលិតរថយន្ត និងដែកថែប

កំពុងដំណើរការយ៉ាងសកម្ម ។ ការអភិវឌ្ឍវិស័យឧស្សាហកម្មនេះបានទាក់ទាញទុនវិនិយោគដ៏ច្រើនពីប្រទេសមហាអំណាចឧស្សាហកម្ម ដូចជាសហរដ្ឋអាមេរិច និងជប៉ុនជាដើម ។

- នៅឆ្នាំ 1990 នាយករដ្ឋមន្ត្រីមហាធាបានប្រកាសគម្រោងផែនការ 30 ឆ្នាំមួយដ៏ធំសម្បើមឈ្មោះ ចក្ខុវិស័យឆ្នាំ 2020 ដើម្បីកែច្នៃប្រទេសម៉ាឡេស៊ីទៅជាប្រទេសដែលមានសេដ្ឋកិច្ច សីលធម៌ និងនយោបាយដ៏ល្អមួយនៅលើពិភពលោក ។
  - ពង្រីកមុខជំនាញបច្ចេកទេសទាំងខ្នាតតូចនិងខ្នាតមធ្យមឱ្យបានច្រើន ដើម្បីបង្កើតទីផ្សារការងារឱ្យបានទូលាយ ។
  - ដឹកនាំប្រទេសឱ្យក្លាយជាប្រទេសពាណិជ្ជកម្មមួយដែលមានការប្រណាំងប្រជែងជាមួយពិភពខាងក្រៅ ផ្អែកលើពាក្យស្លោក "ទីពឹងខ្លួនឯង" ។
  - ផ្អែកលើការប្រឹងប្រែងកសាង ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសលើវិស័យគមនាគមន៍ ទូរគមនាគមន៍ និងថាមពល ។

មេរៀនទី

## ៣ ប្រទេសសិង្ហបុរី

## សំណួរ-ចម្លើយ

**១. ចូរបញ្ជាក់ទីតាំងប្រទេសសិង្ហបុរីនិងឈ្មោះអ្នកបង្កើតទីក្រុងនេះនៅក្នុងសម័យទំនើប។**

**ចម្លើយ**

+ ប្រទេសសិង្ហបុរីជាប្រជុំកោះតូចៗ ស្ថិតនៅចុងខាងត្បូងនៃឧបទ្វីបម៉ាលេ មានផ្ទៃដីក្រលាសរុប 647 $km^2$ ។
+ អ្នកបង្កើតទីក្រុងនេះគឺ **លី ក្វាន់យូ** ។

**២. តើអ្នកណាជាអ្នកដឹកនាំដ៏ល្បីល្បាញ? ចូរនិយាយអំពីនយោបាយដឹកនាំ។**

**ចម្លើយ**

+ អ្នកដឹកនាំដ៏ល្បីល្បាញគឺលោក **លី ក្វាន់យូ** ។
+ នយោបាយដឹកនាំរបស់លោក លី ក្វាន់យូ គឺ

ក្រោយពីបានបញ្ចប់ការសិក្សានៅប្រទេសអង់គ្លេសលោក លី ក្វាន់យូ បានចូលប្រឡូកក្នុងឆាកនយោបាយ។ នៅឆ្នាំ 1954 គាត់បានបង្កើតគណបក្សសកម្មភាពប្រជាជន ដែលគាំទ្រដោយ

ជនជាតិចិនមានទំនោរទៅរកសរបបសង្គមប្រជាធិបតេយ្យ។ លោកលីក្វាន់យូ បានអនុវត្តនយោបាយដាច់ខាតមួយ ដើម្បីសម្រេចនយោបាយសេដ្ឋកិច្ច និងត្រូវអ្នកទាំងអស់គាំទ្រ។ ការកសាងប្រទេស គឺចាប់ផ្ដើមពីចំណុចឧស្សាហកម្ម ដែលមានបីដំណាក់កាល គឺ

- បង្កើតឧស្សាហកម្មដែលស្រូបកម្លាំងពលកម្មច្រើន ដើម្បីកាត់បន្ថយជនឥតការធ្វើ។
- បន្ថែមម៉ោងធ្វើការជាអតិបមា ដើម្បីរកប្រាក់ចំណូលឱ្យបានច្រើននិងសន្សំប្រាក់ខ្លះ។
- បង្កើតឧស្សាហកម្មដែលប្រើបច្ចេកវិទ្យាខ្ពស់និងទំនើប ដើម្បីផ្ដល់ចំណេះដឹងដល់មនុស្សជំនាន់ក្រោយ។

គម្រោងនេះរដ្ឋាភិបាលនឹងអនុវត្តផ្ដល់ជំរកថ្មីដល់ពលរដ្ឋឱ្យបាន 90% និងឈានដល់ 100% នៅដើមសតវត្សទី 21 ។

+ ក្នុងវិស័យអប់រំ រដ្ឋាភិបាលបានដកយកថវិការដ្ឋ 20% ដើម្បីជំរុញវិស័យនេះឱ្យមានការរីកចម្រើន គឺបំបាត់គ្រោះមិនចេះអក្សរ តម្រូវឱ្យប្រជាជនសិង្ហបុរីបានចូលរៀនទាំងអស់គ្នា។ ចំណែកស្ត្រីភេទរឹតតែសំខាន់ ត្រូវចូលរៀនសាលារៀនឱ្យចប់

ថ្នាក់ឧត្តមសិក្សា ព្រោះស្ត្រីជាអ្នកបន្តពូជវ័យឆ្លាតសម្រាប់មនុស្សជំនាន់ក្រោយ ។

**៣. តើហេតុអ្វីបានជាប្រទេសសិង្ហបុរី មានការរីកចម្រើនខាងវិស័យទេសចរណ៍?**

**ចម្លើយ** បានជាប្រទេសសិង្ហបុរី មានការរីកចម្រើនខាងវិស័យទេសចរណ៍ ព្រោះ

- មានការលូតលាស់ផ្នែកសណ្ឋាគារនៅលើទីតាំងជំនួញសម្រាប់ពាណិជ្ជកម្មយ៉ាងមមាញឹក ។
- មានទស្សនីយភាពសម្រាប់ទាក់ទាញពួកទេសចរមិនឱ្យធុនទ្រាន់ តាមរយៈកំពង់ផែ ដែលមានសកម្មភាពរស់រវើកឥតឈប់ឈរ ។
- សិង្ហបុរីមានសំណង់វប្បធម៌ដ៏ល្បីល្បាញដូចជាបណ្ណាល័យជាតិ សារមន្ទីរជាតិ និងសាកលវិទ្យាល័យ ។
- នៅកណ្តាលក្រុងចាស់ក៏មានវត្ថុវិចិត្រអប់ដោយស្ថាបត្យកម្មទំនើបលាយឡំទៅដោយអាគារចាស់ៗ ពីសម័យអាណានិគម និងទីសក្ការបូជាជាច្រើនកន្លែង ។
- ទីក្រុងសិង្ហបុរីសម្បូរទៅដោយប្រព័ន្ធផ្លូវរថយន្តក្រុងនិងផ្លូវ

ក្រោមដី ដែលជួយសម្រួលដល់អ្នកដំណើរមិនឱ្យកកស្ទះ ហើយនៅជិតក្រុងនេះក៏មានអាកាសយានដ្ឋានអន្តរជាតិមួយឈ្មោះចាន់ហ្គី ។

**៤. តើហេតុអ្វីបានជាគេនិយាយថា សិង្ហបុរីជាកូននាគមួយក្នុងចំណោមកូននាគទាំង 4 នៅទ្វីបអាស៊ី?**

**ចម្លើយ**

បានជាគេនិយាយថា សិង្ហបុរីជាកូននាគមួយក្នុងចំណោមកូននាគទាំង 4 នៅទ្វីបអាស៊ី ព្រោះប្រទេសនេះមានការរីកចម្រើនលើគ្រប់វិស័យដូចជា វិស័យកសិកម្ម ឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម វិស័យដឹកជញ្ជូន។ ក្នុងនោះយើងសង្កេតឃើញថាប្រទេសសិង្ហបុរីមានដៃគូពាណិជ្ជកម្មជាមួយប្រទេសនៅលើពិភពលោកចំនួន 132 កំណើតពាណិជ្ជកម្មនេះត្រូវមើលឃើញតាមរយៈសកម្មភាពនៃកំពង់ផែដែលកើតឡើងពី 60 លានតោន រហូតដល់ 190 លានតោនក្នុងមួយឆ្នាំ។ ប្រទេសដែលជាដៃគូពាណិជ្ជកម្មធំជាងគេ គឺសហរដ្ឋអាមេរិចប្រទេសនៅអឺរ៉ុបនិងជប៉ុន។ ម្យ៉ាងវិញទៀតប្រទេសនេះមានផលិតផលជាតិសរុបសម្រាប់មនុស្សម្នាក់ស្មើនឹង 12000$ ។

មេរៀនទី

# ៤ ប្រទេសភីលីពីន

## សំណួរ -ចម្លើយ

**១. តើប្រទេសភីលីពីនធ្លាប់នៅក្រោមអាណានិគមនិយមណាខ្លះ? តើអាណានិគមនិយមនីមួយៗមានភាពខុសគ្នាដូចម្ដេច? ហើយអាណានិគមណាដែលប្រសើរជាងគេ?**

**ចម្លើយ**

\+ ប្រទេសភីលីពីនធ្លាប់នៅក្រោមអាណានិគមនិយមអេស្ប៉ាញ ជប៉ុន និងសហរដ្ឋអាមេរិច ។

\+ ភាពខុសគ្នានៃអាណានិគមនីមួយៗ គឺ :

**ក. អេស្ប៉ាញ**

- មានគោលដៅពង្រីកឥទ្ធិពលគ្រិស្តសាសនានៅអាស៊ីអាគ្នេយ៍ ។
- មានការប្រកាន់ពូជសាសន៍ដែលនាំឱ្យមានអំពើហិង្សាកាប់ស្លាប់ ពួកមេដឹកនាំសាសនា និងការប្លន់យកដីធ្លីពីសំណាក់ពួកបព្វជិត ។

ខ. អាមេរិច

មានទិសដៅពង្រីកឥទ្ធិពលមហាអំណាចខ្លួន តាមរយៈការផ្សព្វផ្សាយ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ដែលគេនិយាយថាជាបេសកម្មប្រជាធិបតេយ្យ។ សហរដ្ឋអាមេរិចបានចំណាយថវិកាជាច្រើន ដើម្បីជួយប្រទេសភីលីពីនលើវិស័យអប់រំ សុខាភិបាល និងសេដ្ឋកិច្ច។

គ. ជប៉ុន

ដើម្បីគ្រប់គ្រងប្រទេសនៅអាស៊ី ដែលមានពាក្យស្លោកថា "ទ្វីបអាស៊ីសម្រាប់ជនជាតិអាស៊ី" និង "ជប៉ុនជាពន្លឺសម្រាប់ទ្វីបអាស៊ី ព្រោះវាស្ថិតក្នុងតំបន់ប្រតិបត្តិការរួមគ្នា"។

\+ អាណានិគមដែលមានលក្ខណៈប្រសើរជាងគេ គឺ អាណានិគមអាមេរិច។

២. តើសហរដ្ឋអាមេរិចបានត្រួតត្រាប្រទេសភីលីពីននៅពេលណា? ហើយបានបន្សល់ទុកនូវគ្រឹះអ្វីខ្លះ ដើម្បីកសាងប្រទេសភីលីពីនឱ្យរីកចម្រើន?

**ចម្លើយ**

+ សហរដ្ឋអាមេរិចបានត្រួតត្រាប្រទេសភីលីពីននៅឆ្នាំ 1898 ។
+ ដើម្បីកសាងប្រទេសភីលីពីនឱ្យរីកចម្រើនសហរដ្ឋអាមេរិចបានបន្សល់ទុក

## ក. វិស័យសេដ្ឋកិច្ច

- សហរដ្ឋអាមេរិចបានបោះទុនវិនិយោគនៅមុនឆ្នាំ 1940 ចំនួនទឹកប្រាក់140លានដុល្លា ដើម្បីជួយប្រទេសភីលីពីនលើវិស័យកសិកម្ម ដូចជាដំណាំអំពៅ ថ្នាក់ជក់ និងក្រចៅជាដើម ។
- ពង្រីកផ្ទៃដីកសិកម្មនិងរោងចក្រឧស្សាហកម្ម ដែលជាកត្តាជួយលើកតម្កើងកម្រិតជីវភាពពួកកសិករនិងកម្មករភីលីពីន ។
- ដើម្បីសម្រួលនាំចេញ ក៏មានការស្ថាបនាផ្លូវរថភ្លើងនៅតាមតំបន់ឆ្នេរផងដែរ ។

## ខ. វិស័យសុខាភិបាល

- សហរដ្ឋអាមេរិចបានបង្កើតនូវគិលានុប្បដ្ឋានចំនួន 1000 ព្រមទាំងមន្ទីរពេទ្យចំនួន 40 ទៀត នៅតាមជនបទ និងទីក្រុងធំៗពាសពេញប្រទេសភីលីពីន ។ មន្ទីរពេទ្យទាំងនេះបានបើកពិនិត្យព្យាបាលជំងឺ និងចែកចាយឱសថសម្រាប់ថែរក្សាសុខ

ភាពដល់ប្រជាពលរដ្ឋភីលីពីនទូទៅ ដោយគ្មានរើសអើង។

**គ. វិស័យអប់រំ**

- នៅឆ្នាំ 1901 សហរដ្ឋអាមេរិចបានផ្ដល់គ្រូជនជាតិអាមេរិច ចំនួន 600 នាក់ ត្រៀមជំនួសគ្រូអាមេរិច ដែលត្រូវធ្វើមាតុភូមិនិវត្តន៍។
- នៅក្នុងសង្គ្រាមលោកលើកទី 2 ភីលីពីន មានមនុស្សចូលរៀនក្នុងសាលាចំនួន 50% ខ្ពស់ជាងប្រទេសជប៉ុន និងប្រទេសនៅជិតខាង។

**៣. តើរបបដឹកនាំម៉ាកូសជារបបអ្វី? ចូរពន្យល់។**

**ចម្លើយ**

របបដឹកនាំម៉ាកូសជារបបផ្ដាច់ការនិងគ្រួសារនិយម។ នៅក្រោយពេលប្រកាសច្បាប់អាជ្ញាសឹកម៉ាកូសបានបិទកាសែត ហើយចាប់អ្នកប្រឆាំងរាប់រយនាក់ដាក់គុក ក្នុងនោះក៏មានលោកបេនីញ៉ូ អាគីណូ ដែលជាមេដឹកនាំគណបក្សប្រឆាំងដ៏ធំផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍ ត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹង។

**៤. ហេតុអ្វីបានជារបបម៉ាកូសត្រូវដួលរលំ?**

**ចម្លើយ**

បានជារបបម៉ាកូសត្រូវដួលរលំ ដោយសារការបាញ់ប្រហារលោកអាគីណូ នៅអាកាសយានដ្ឋានក្រុងម៉ានីលនៅថ្ងៃទី 21 ខែសីហា ឆ្នាំ ១៩៨3 ក្នុងដំណើរវិលត្រឡប់ពីសហរដ្ឋអាមេរិចចូលរួមប្រជែងតំណែងប្រធានាធិបតីភីលីពីន។

# មេរៀនទី

## ៥ ប្រទេសកូរ៉េ

### សំណួរ -ចម្លើយ

**១. តើហេតុអ្វីបានជាប្រទេសកូរ៉េត្រូវបែងចែកជាពីរ?**

**ចម្លើយ** បានជាប្រទេសកូរ៉េត្រូវបែងចែកជាពីរ ព្រោះ

- លុះសង្គ្រាមលោកលើកទី 2 ជប៉ុនបានចាញ់សង្គ្រាមលោក ទើបមហាអំណាចទាំងពីរបានចូលលុកលុយប្រទេសកូរ៉េដែលជាដែនដីអាណានិគមរបស់ប្រទេសជប៉ុន។
- សហភាពសូវៀតបានត្រួតត្រាផ្នែកខាងជើងនៃឧបទ្វីប ចំណែកសហរដ្ឋអាមេរិចបានគ្រប់គ្រងផ្នែកខាងត្បូងនៃឧបទ្វីប។
- នៅឆ្នាំ 1947 មហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់អនុម័តឱ្យមានការបង្រួបបង្រួមប្រទេសកូរ៉េតែមួយ។ ប៉ុន្តែសហភាពសូវៀតបានជំទាស់ដោយមិនអនុញ្ញាតឱ្យមានការបោះឆ្នោតនៅឧបទ្វីបកូរ៉េបែកខាងជើង។
- នៅថ្ងៃទី 10 ខែឧសភា ឆ្នាំ1948 ប្រជាជនកូរ៉េខាងត្បូងបានបោះឆ្នោតជ្រើសរើសសភាហើយសភាក៏បានបោះឆ្នោតបង្កើតរដ្ឋាភិបាលខាងត្បូងមួយ។

- ដើម្បីឆ្លើយតប កូរ៉េខាងជើងបានប្រកាសបង្កើតសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េខាងជើងនៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ1948 ។
- ចាប់តាំងពីពេលនោះមក កូរ៉េខាងជើងនិងខាងត្បូងសុទ្ធតែបានប្រកាសថា ជារដ្ឋតំណាងឧបទ្វីបកូរ៉េរៀងៗខ្លួន និងបានចាប់បញ្ជូនទ័ពរបស់ខ្លួនទៅព្រំដែនជាបន្តបន្ទាប់ចាប់ពីឆ្នាំ 1948-1950 ។
- សង្គ្រាមកូរ៉េផ្ទុះឡើងចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥០ ហើយបញ្ចប់ទៅវិញនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៥៣ ដែលគូបដិបក្សទាំងសងខាងបានចុះកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាម ។

ដូចនេះកូរ៉េបែកជាពីរដោយសារលទ្ធិគ្រប់គ្រងប្រទេសខុសគ្នាគឺកូរ៉េខាងជើងបែបកុម្មុយនីស និងកូរ៉េខាងត្បូងបែបប្រជាធិបតេយ្យសេរី ។

**២. តើប្រទេសកូរ៉េទាំងពីរនេះមានគោលនយោបាយដូចម្តេចខ្លះ?**

**ចម្លើយ**

+ **កូរ៉េខាងត្បូង** : ជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។
- ប្រទេសកូរ៉េខាងត្បូងជាសាធារណរដ្ឋដែលមានរដ្ឋាភិបាលឡើងកាន់អំណាចជ្រើសរើសតាំងដោយប្រជាពលរដ្ឋ ។

- រដ្ឋធម្មនុញ្ញបានចែងច្បាស់អំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិនិងសេរីភាពខាងជំនឿ . ជាពិសេសការគោរពសាសនា ។
- ប្រធានាធិបតីជាអ្នកដឹកនាំប្រទេស គឺជាប្រមុខរដ្ឋនិងជាប្រមុខរដ្ឋាភិបាលដែលជ្រើសរើសតាំងដោយការបោះឆ្នោតមានអាណត្តិ 5 ឆ្នាំ បុគ្គលម្នាក់ពុំអនុញ្ញាតិឱ្យឈរឈ្មោះ 2 ដងសម្រាប់តំណែងប្រធានាធិបតីឡើយ ។
- ប្រមុខរដ្ឋ ជាអ្នកតែងតាំងនាយករដ្ឋមន្ត្រីនិងគណៈរដ្ឋមន្ត្រីជ្រើសសម្រាប់ដឹកនាំក្រសួងនីមួយៗ ដែលមានសមាជិករហូតដល់ 30 រូប ។
- សភាជាតិមាន 299 រូបដែលជ្រើសតាំងដោយសំឡេងឆ្នោតរបស់ប្រជាពលរដ្ឋមានអាណត្តិ 4 ឆ្នាំ និងជាអង្គការនីតិបញ្ញត្តិដែលជាស្ថាប័នកំពូលសម្រាប់អនុម័តច្បាប់ ។

\+ **កូរ៉េខាងជើង** : ដឹកនាំប្រទេសបែបកុំមុយនីស ។

- រដ្ឋធម្មនុញ្ញកូរ៉េខាងជើងផ្តល់សិទ្ធិអំណាចគ្រប់បែបយ៉ាងដល់ប្រជាជន ប៉ុន្តែជាក់ស្តែងគណបក្សកុំមុយនីស ឬហៅថាគណ

បក្សពលករកូរ៉េ ដែលជាអ្នកកាន់អំណាចពុំទាន់បានផ្តល់សិទ្ធិអំណាចគ្រប់បែបយ៉ាងដល់ប្រជាជនកូរ៉េឡើយ ។

- គណបក្សកូរ៉េដឹកនាំដោយលោក គីមអ៊ិលស៊ុង ជាប្រមុខរដ្ឋ និងជាអគ្គលេខានៃមជ្ឈិមបក្សកុម្មុយនីសកូរ៉េ ។ គណៈកម្មាធិការមជ្ឈិមបក្សដែលជាមន្ត្រីជាន់ខ្ពស់ និងអ្នកមានស្នាដៃបដិវត្តន៍ចំនួន 20 រូប ជ្រើសតាំងដោយសភាប្រជាជនដែលមានសមាជិក 687 រូប បោះឆ្នោតជ្រើសតាំងដោយប្រជាជនមានអាណត្តិ 4 ឆ្នាំ ។
- សភាមានអំណាចតិចតួច ហើយកោះប្រជុំតែមួយ ឬពីរសប្តាហ៍ប៉ុណ្ណោះក្នុងមួយឆ្នាំ តាមតម្រូវការរបស់គណៈកម្មាធិការមជ្ឈិមបក្ស ។

**៣. តើសង្គ្រាមកូរ៉េមានរយៈពេលប៉ុន្មានឆ្នាំ? មានផលវិបាកអ្វីខ្លះ?**

**ចម្លើយ**

+ សង្គ្រាមកូរ៉េមានរយៈពេល 3 ឆ្នាំ ។
+ មានផលវិបាក ដូចជា :
  - ប្រជាជនកូរ៉េខាងត្បូងប្រហែល 1 លាននាក់បានស្លាប់និងជាច្រើនលាននាក់ទៀតបានបាត់បង់ទីជំរក ។

- ការខូចខាតនៅលើសមរភូមិមានទំហំធំធេងមិនចាញ់សង្គ្រាមលោកលើកទី ៃ ឡើយ ។
- សហរដ្ឋអាមេរិចបានបាត់បង់យន្តហោះជាង 2000 គ្រឿង ដោយសារការបាញ់ទំលាក់របស់ពួកកុំមុយនីស ។
- សហភាពសូវៀត ក៏បានបាត់បង់យន្តហោះជាច្រើនគ្រឿងដែរ ជាពិសេសគឺមិច 15 អស់ជាង 1000 គ្រឿង ដោយការបាញ់ពីលើអាកាសរបស់កងយន្តហោះសហរដ្ឋអាមេរិច ។

**៤. តើទំនាក់ទំនងនៃកូរ៉េទាំងពីរមានអ្វីខ្លះ?**

**ចម្លើយ** ទំនាក់ទំនងនៃកូរ៉េទាំងពីរមានទំនាក់ទំនងភាពជាបងប្អូន (ជនជាតិកូរ៉េដូចគ្នា) ទំនាក់ទំនងផ្នែកសេដ្ឋកិច្ច ។

**៥. តើបច្ចុប្បន្នប្រទេសកូរ៉េទាំងពីរកំពុងមានបញ្ហាប្រឈមមុខគ្នាអ្វីខ្លះ?**

**ចម្លើយ** បច្ចុប្បន្នប្រទេសកូរ៉េទាំងពីរកំពុងមានបញ្ហាប្រឈមមុខគ្នាលើបញ្ហា :

- បញ្ហាយោធា
- បញ្ហាបរមាណូ
- បញ្ហារបបគ្រប់គ្រងកុំមុយនីស និងលទ្ធិប្រជាធិបតេយ្យ
- បញ្ហាកូរ៉េខាងជើងបាញ់កម្ទេចនាវាកូរ៉េខាងត្បូង . . . ។

មេរៀនទី

## ៦ ប្រទេសញូសេឡែន

## សំណួរ -ចម្លើយ

**១. តើជនជាតិណាជាអ្នករកឃើញប្រទេសញូសេឡែនមុនគេ? ប្រទេសនេះស្ថិតនៅឯណា? មានស្ថានភាពដូចម្តេចខ្លះ?**

**ចម្លើយ**

+ ជនជាតិដែលរកឃើញប្រទេសញូសេឡែនមុនគេ គឺជនជាតិហូឡង់ ឈ្មោះ **អាបែលថនស៊ុន តាស្មាន់** ( ឆ្នាំ 1642) ។
+ ប្រទេសនេះស្ថិតនៅក្នុងចំណោមទិប្រជុំកោះប៉ាស៊ីភិច ដែលពីមុនហៅថាទ្វីបអូសេអានី ឥឡូវហៅថាអាស៊ីប៉ាស៊ីភិច ។
+ ស្ថានភាព គឺ

ប្រទេសញូសេឡែនមានកោះធំៗចំនួន 2 គឺកោះខាងជើង និងកោះខាងត្បូង ដែលចែកខណ្ឌគ្នាដោយច្រកសមុទ្រឃុក ក្រៅពីនេះនៅមានកោះតូចៗមួយចំនួនទៀត ដែលស្ថិតនៅក្នុងលំហសមុទ្រប៉ាស៊ីភិច។ ប្រទេសនេះមានក្រុងធំៗ 5 គឺ វ៉េលលីងតោន ដែលជារដ្ឋធានី ទីក្រុងបន្ទាប់ឈ្មោះអកឡិន គ្រីស្តឆើចឌូនឌីន និងម៉ានូកូវ ។ ញូសេឡែនជាប្រទេសល្អឆើតឆាយទៅ

ដោយជួរភ្នំដែលគ្របដណ្តប់ទៅដោយព្រៃលិចនិងលាតសន្ធឹងដោយ វាលស្មៅខ្ចី ឆ្នេរខ្សាច់ បឹងបួរ និងព្រៃព្រឹក្សា ប៉ុន្តែសម្បូរទៅ ដោយភ្នំភ្លើង។

**២. តើហេតុអ្វីបានជាប្រទេសនេះមានភ្នំភ្លើងនិងការរញ្ជួយដីច្រើន?**

**ចម្លើយ**

បានជាប្រទេសនេះមានភ្នំភ្លើង និងការរញ្ជួញដីច្រើន ព្រោះ ដោយសារប្រទេសនេះស្ថិតនៅចំតំបន់អាស៊ីប៉ាស៊ីភិច ដែលក្នុង មួយឆ្នាំមានការរញ្ជួយដីរហូតដល់ ៤០០ លើក ក្នុងនោះមាន ១០០ លើកមានទ្រង់ទ្រាយធំ ដែលបង្កមហន្តរាយដល់មនុស្ស និងផ្ទះ សំបែង។

**៣. តើគ្រឹះសេដ្ឋកិច្ចនៃប្រទេសញូសេឡែនមានអ្វីខ្លះ?**

**ចម្លើយ** គ្រឹះសេដ្ឋកិច្ចនៃប្រទេសញូសេឡែន មាន :

- ផលិតផលកសិកម្ម និងពាណិជ្ជកម្មក្រៅប្រទេស : ផលិតផល នាំចេញទៅលើទីផ្សារអន្តរជាតិ ប័រ ប្រូម៉ា សាច់ និងរោម ចៀម ជាពិសេសទៅប្រទេសអង់គ្លេសទទួលប្រាក់បានចំណូល យ៉ាងច្រើន។

- ផលិតផលឧស្សាហកម្ម : រកប្រាក់ចំណូលមិនចាញ់ប្រាក់ចំណូលកសិកម្មដែរ ។

**៤. តើភាពលូតលាស់នៃសេដ្ឋកិច្ចបានជំរុញឱ្យប្រទេសនេះមានការរីកចម្រើនអ្វីខ្លះ ដែលនាំមុខគេនៅលើពិភពលោក?**

**ចម្លើយ** ភាពលូតលាស់នៃសេដ្ឋកិច្ចបានជំរុញឱ្យប្រទេសនេះ មានការរីកចម្រើន :

- សាច់ និងទឹកដោះគឺជាចំណីអាហារដ៏សម្បូរហូរហៀរសម្រាប់ជនជាតិញូសេឡែន។ ផលិតផលលើសពីតម្រូវការក្នុងស្រុកគេ បាននាំចេញច្រើនជាងគេទៅកាន់ទីផ្សារពិភពលោក ។
- ស្រូវសាលី និងពោតគ្រប់ប្រភេទ . . .
- ក្រៅពីសាច់សត្វគេនាំចេញ ទឹកដោះ សាច់ត្រី ក្តារបន្ទះក្រាស ។

មេរៀនទី

## ៧ ប្រទេសអូស្ត្រាលី

## សំណួរ -ចម្លើយ

**១. តើជនជាតិអឺរ៉ុបទៅដល់ទឹកដីអូស្ត្រាលីដំបូងឈ្មោះអ្វី?**

**ចម្លើយ**

ជនជាតិអឺរ៉ុបទៅដល់ទឹកដីអូស្ត្រាលីដំបូងឈ្មោះ . **ជេមឃុប** (ឆ្នាំ1770) ។

**២. តើលោកអាធូរភីលីពទៅអូស្ត្រាលីតាមមធ្យោបាយអ្វី? ក្នុងបំណងធ្វើអ្វី?**

**ចម្លើយ**

\+ លោកអាធូរភីលីពទៅអូស្ត្រាលីតាមនាវា ៣ គ្រឿង ។

\+ ក្នុងគោលបំណង : យកទណ្ឌិត (អ្នកទោស) ចំនួន 717 នាក់ ក្នុងនោះស្ត្រីចំនួន 118 នាក់ មកទម្លាក់នៅកំពង់ផែហ្សាក់សុន គឺជាទីតាំងនៃក្រុងស៊ីដនីសព្វថ្ងៃ ។

**៣. តើអូស្ត្រាលីជាប្រទេសកសិកម្ម ឬ ជាប្រទេសឧស្សាហកម្ម? ព្រោះអ្វី?**

**ចម្លើយ**

អូស្ត្រាលីជាប្រទេសកសិកម្ម ព្រោះប្រទេសនេះពឹងផ្អែកលើការនាំចេញសាច់ ទឹកដោះ រោមសត្វ និងស្រូវសាលីដ៏ធំទៀតផង។

**៤. តើប្រទេសណាខ្លះ ជាដៃគូពាណិជ្ជកម្មសំខាន់ជាងគេរបស់អូស្ត្រាលី?**

**ចម្លើយ**

ប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ជាងគេរបស់អូស្ត្រាលី មាន អង់គ្លេស ជប៉ុន កូរ៉េ តៃវ៉ាន់ សិង្ហបុរី និងហុងកុង។

**៥. ចូរបួនអធិប្បាយពីវិស័យឧស្សាហកម្មទេសចរណ៍អូស្ត្រាលី។**

**ចម្លើយ**

វិស័យទេសចរណ៍ជាឧស្សាហកម្មមួយផ្តល់ប្រភពចំណូលដ៏ធំមួយដែរ។ លំហូរភ្ញៀវទេសចរណ៍បានកើននៅពេលក្រោយសង្គ្រាមលោកលើកទី 2 គឺ 2.5 លាននាក់ រហូតដល់ ៦.5 លាននាក់ ភាគច្រើននៃភ្ញៀវទាំងនោះគឺមកពីទ្វីបអាស៊ី។ នៅក្នុងឧស្សាហកម្មទេសចរណ៍ក៏មានទុនវិនិយោគមកពីជប៉ុន ម៉ាឡេស៊ី និងសិង្ហបុរីសម្រាប់អភិវឌ្ឍន៍សំណង់សណ្ឋាគារលំដាប់ផ្កាយបីជាច្រើនកន្លែង។

## ?សំណួរចម្លាប់ជំពូកទី៣

I. *ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយដែលត្រឹមត្រូវ*

១. តើលោកស៊ូកាណូបានបង្កើតគណបក្សជាតិនិយមឥណ្ឌូនេស៊ីនៅឆ្នាំណា?

☐ក. 1925 ☐ខ. 1926

☑គ. 1927 ☐ឃ. 1928

២. តើប្រទេសម៉ាឡេស៊ីទទួលបានឯករាជ្យពីអង់គ្លេសនៅឆ្នាំណា?

☑ក. 1963 ☐ខ. 1964

☐គ. 1965 ☐ឃ. 1962

៣. តើប្រទេសសិង្ហបុរីបានផ្តាច់ខ្លួនពីសហព័ន្ធម៉ាឡេស៊ីនៅឆ្នាំណា?

☐ក. 1964 ☑ខ. 1965

☐គ. 1966 ☐ឃ. 1967

៤. តើលោកម៉ាកូសជាប់ឆ្នោតជាប្រធានាធិបតីនៃប្រទេសភីលីពីនលើកទី1 នៅឆ្នាំណា?

☑ក. 1965 ☐ខ. 1966

☐គ. 1967 ☐ឃ. 1969

II. *ចូរជ្រើសរើសពាក្យ ក្នុងក្រោមពាក្យឆ្នាំ ឬឈ្មោះទៅបំពេញឈ្មោះខាងក្រោម*

(1931 , 1852 , លោកជេមឃុក , បដិវត្តន៍បៃតង , ម៉ាលេ , ចិន , ឥណ្ឌា)

១. ប្រទេសញូវសេឡែនស្ថិតនៅក្រោមអាណានិគមអង់គ្លេសនៅឆ្នាំ...**1852**...។

២. ប្រទេសញូវសេឡែនបានទទួលឯករាជ្យពីអង់គ្លេសនៅឆ្នាំ...**1931**...។

៣. លោក ...***ជេមឃុក***... បានរកឃើញទឹកដីអូស្ត្រាលីដំបូងនៅឆ្នាំ 1770។

៤. លោកស៊ូកាណូលើកផែនការ 5 ឆ្នាំ (1969-1974) ដើម្បីធ្វើ...***បដិវត្តន៍បៃតង***...។

III. *ចូរគូសភ្ជាប់ ឬ ផ្គូផ្គងពីឈ្មោះប្រទេសទៅរាជធានី ឬ រដ្ឋធានី*

| ឈ្មោះប្រទេស | រាជធានី ឬ រដ្ឋធានី | ចម្លើយ |
|---|---|---|
| ១. ញូវសេឡែន | ក. ចាការតា | ១. →ង |
| ២. ឥណ្ឌូនេស៊ី | ខ. កានបេរ៉ា | ២. →ក |
| ៣. ម៉ាឡេស៊ី | គ. សាំងគាពូរ | ៣. →ឃ |

| | | |
|---|---|---|
| ៤. អូស្ត្រាលី | ឃ. កូឡាឡាំពួរ | ៤. → ខ |
| ៥. សិង្ហបុរី | ង វៀលលីងតុន | ៥. → គ |

## IV. សំណួរត្រិះរិះ

**១. តើហេតុអ្វីបានជាប្រទេសកូរ៉េឈ្មោះគ្នាហើយបែកជាពីរ? ចូរពន្យល់ ។**

**ចម្លើយ** បានជាប្រទេសកូរ៉េត្រូវបែងចែកជាពីរ ព្រោះ

- ជប៉ុនបានត្រួតត្រាកូរ៉េនៅឆ្នាំ ១៨៧៥ រួចបញ្ចូលប្រទេសកូរ៉េជាផ្នែកមួយនៃប្រទេសរបស់ខ្លួននៅឆ្នាំ ១៩១០ ។
- លុះសង្គ្រាមលោកលើកទី 2 ជប៉ុនបានចាញ់សង្គ្រាមលោក ទើបមហាអំណាចទាំងពីរបានចូលលុកលុយប្រទេសកូរ៉េដែលជាដែនដីអាណានិគមរបស់ប្រទេសជប៉ុន ។
- សហភាពសូវៀតបានត្រួតត្រាផ្នែកខាងជើងនៃឧបទ្វីប ចំណែកសហរដ្ឋអាមេរិចបានគ្រប់គ្រងផ្នែកខាងត្បូងនៃឧបទ្វីប ។
- នៅឆ្នាំ 1947 មហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់អនុម័តឱ្យមានការបង្រួបបង្រួមប្រទេសកូរ៉េតែមួយ ។ ប៉ុន្តែសហភាពសូវៀតបានជំទាស់ដោយមិនអនុញ្ញាតឱ្យមានការបោះឆ្នោតនៅឧបទ្វីបកូរ៉េបែកខាងជើង ។

២. ប្រទេសអូស្ត្រាលីមានទឹកដីធំជាង ហេតុអ្វីក៏មិនមែនជាប្រទេសមហាអំណាច?

**ចម្លើយ** ប្រទេសអូស្ត្រាលីមានទឹកដីធំ បានជាប្រទេសនេះមិនមែនជាប្រទេសមហាអំណាច ព្រោះ

- មានចំនួនប្រជាជនតិច
- សេដ្ឋកិច្ចមិនទាន់រឹងត្រាប់ដណ្តប់លើពិភពលោក
- នយោបាយមិនទាន់មានភាពខ្លាំងក្លា
- កម្លាំងយោធានៅមានលក្ខណៈទន់ខ្សោយនៅឡើយ . . . ។

# ចេះពីរៀន មានពីរក

សូមអរគុណ!